## វលាហស្សជាតក លេខ ១៩៦

ព្រះឧត្តមមុនី អ៊ុម-ស៊ូរ អាចារ្យព្រះរាជបណ្ណាល័យកម្ពុជា

ប្រែពីបាឡីមកជាភាសាខ្មែរ

COMMISSION DES MŒURS & COUTUMES

វលាហស្សជាតក លេខ ១៩៦

នឹងសំដែងអំពីវលាហសជាតក តាមបទបាឡីថា យេនកាហន្តិឱវាទន្តិ ដូច្នេះជាដើម ។ សេចក្តីក្នុងបាឡីជាតកនោះថា ក្នុងវេលាមួយនោះព្រះបរមសាស្តាជាគ្រូនៃយើងព្រះអង្គទ្រង់គង់នៅវត្តជេតវនារាម បានសំដែងនូវធម៌ទេសនា ១ បទនោះថា យេនកាហន្តិឱវាទន្តិ ដូច្នេះជាដើមបំពោះនឹងភិក្ខុម្នាក់ជាអ្នកអប្បុកបាកធម៌វិន័យក្នុងព្រះពុទ្ធសាសនា ។ គ្រានោះព្រះសម្មាសម្ពុទ្ធទ្រង់ឲ្យហៅភិក្ខុនោះចូលមកគាល់ លុះចូលមកដល់ហើយព្រះអង្គក៏ត្រាស់សួរថា នែភិក្ខុអ្នកឯងមានចិត្តរាយមាយរវើរវាយ មិនសប្បាយក្នុងធម៌នឹងវិន័យរបស់តថាគតមែន

---

(១) ក្នុងមហាសុទស្សនសូត្រថាវលាហក ជាឈ្មោះសេះកែវ ១ សំរាប់ស្តេចចក្រ

ឬអ្វី  ភិក្ខុនោះក៏ក្រាបបង្គំទូលថាពិតមែនដូចព្រះជិមានព្រះភាគទ្រង់ជ្រាបនោះហើយ  ទើបព្រះសម្ពុទ្ធទ្រង់សួរតទៅទៀតថា  បុះហេតុអ្វីក៏អ្នកមិនសប្បាយក្នុងសាសនាតថាគតនេះ  ភិក្ខុនោះទូលថា  ឯហេតុដែលខ្ញុំព្រះករុណាមិនសប្បាយនោះព្រោះខ្ញុំព្រះករុណាបានជួបប្រទះឃើញនូវស្រីម្នាក់  មានរូបរាងល្អព្រមទាំងមានគ្រឿងអលង្ការប្រដាប់សំរាប់កាយដ៏រុងរឿងផង  ហើយខ្ញុំព្រះករុណា  ក៏មានសេចក្ដីស្នេហាកើតឡើងដោយអំណាចនៃកិលេសធម៌នោះឯង  ។

ព្រះបរមគ្រូទ្រង់ត្រាស់សំដែងអំពីសេចក្ដីល្បួងលួងលោមនៃស្រីទាំងឡាយប្រាប់ភិក្ខុនោះថា  នែភិក្ខុ  ជាតិមាតុគ្រាមទាំងឡាយតែងមានឧបាយកល់បេះប្រលោមនូវបុរសទាំងពួងឲ្យវង្វេងស្មារតីរំលមុខភាន់ច្រឡំត្រឡប់ជាតុ  ដោយលំអនៃរូបនិងពីរោះសំឡេង, ក្រអូបក្លិន, ឆ្ងាញ់រសនឹងការពាល់ត្រូវនូវសម្ផស្សទាំងឡាយផង  ដោយឫកញិកញក់កែក្រាយនឹងដំណើរយាងយាសនៃស្រីទាំងឡាយនេះផង  ហើយអាចធ្វើនូវបុរសទាំងអស់គ្នាឲ្យស្ថិតនៅក្នុងអំណាចនៃខ្លួនបាន  មិនឲ្យរើរូសរួចឡើយ

ដោយហេតុនេះហើយបានជាតថាគតឲ្យឈ្មោះនូវស្រីទាំងនោះ ហៅថាយក្ខិណី ព្រោះតែស្រីទាំងនោះតែងធ្វើនូវបុរសដែលមានសីលល្អបរិបូណ៌ឲ្យវិនាសចាកសីលទៅបានផង ធ្វើនូវបុរសដែលមានទ្រព្យសម្បត្តិឲ្យខូចខាតចាកទ្រព្យទាំងនោះទៅផង ។ នែអ្នកបួសបួរអ្នកឯងប្រុងស្តាប់ពាក្យតថាគតៗនឹងប្រាប់អ្នកឲ្យជាក់ច្បាស់ថាដូច្នេះ កាលគ្រាអំពីមុនយូរមកហើយមាននាងយក្ខិណីទាំងឡាយច្រើនរូបចូលទៅរកបុរសអ្នកឈ្មួញ ១ ពួកនោះដើម្បីបែចង់យកធ្វើជាប្តី ហើយក៏និយាយលួងលោមប្រលោមនូវពាណិជអ្នកឈ្មួញទាំងនោះឲ្យលុះក្នុងអំណាចនៃសេចក្តីបំណាចរបស់ខ្លួនតាមប្រាថ្នា តពីនោះមកបានឃើញនូវបុរសទាំងឡាយថ្មីដទៃទៀតចូលមកក៏នាងយក្ខិណីទាំងនោះមានសេចក្តីត្រេកអរនឹងបុរសថ្មីនោះ បែមកវាយដំនូវពាណិជទាំងឡាយជាប្តីដើមនោះ ដោយផ្តួងចង្កាទាំងឡាយឲ្យជាំដាំបែកឈាមរហូរហៀរចេញមកដរាបដល់ពាណិជជាប្តីដើមនោះលុះនូវសេចក្តីមរណភាពក្នុងវេលានោះ ១ រំពេចទៅ ហើយយក្ខិណីក៏ផឹកឈាមទំពាស៊ីសាច់នៃប្តីរបស់ខ្លួនគ្រប់គ្នា ទើបសម្តេចព្រះ-

ភគវាទ្រង់នាំមកនូវអតីតនិទាន ជានិទានដែលកន្លងទៅហើយ នោះមកសំដែងប្រាប់ភិក្ខុទៀតថា អតីតេតម្ពបណ្ណិទីបេ សិរិស· វត្ថុនាម យក្ខនគរំអហោសិ ។ សេចក្ដីថាក្នុងកាលដែលកន្លងរំលងទៅហើយនោះមាននគរនៃយក្ស ១ ឈ្មោះថាសិរិសវត្ថុ ស្ថិតនៅ ៗ កោះឈ្មោះតម្ពបណ្ណិ គឺស្រុកលង្កាទ្វីបសព្វថ្ងៃនេះ ឯសិរិសវត្ថុនគរនោះជាទីលំនៅនៃនាងយក្ខិណីទាំងឡាយច្រើន ឯនាងយក្ខិណីទាំងនោះជាស្រីចូលចិត្តតាក់តែងស្អិតស្អាងរាងកាយដោយគ្រឿងប្រដាប់សំរាប់តែងហើយពរបីនូវកូនតូច ៗ ទាំងឡាយដោយខ្លួនឯងគ្រប់គ្នា បង្គាប់នូវខ្ញុំស្រីទាំងឡាយឲ្យវែកទូលនូវភោជនាហារម្ហូបចំណីហែហមចោមរោមខ្លួនទៅជាមួយផង ចូលទៅរកពួកពាណិជទាំងឡាយ ឯនាងយក្ខិណីទាំងអស់នេះ កាលដែលនឹងចូលកាន់សំណាក់នៃពាណិជទាំងពួងនោះក៏សំដែងរិទ្ធិរបស់ខ្លួន ធ្វើជាមនុស្សទាំងឡាយច្រើនរូប ខ្លះកំពុងភ្ជួរស្រែ ខ្លះកំពុងឃ្វាលគោ ហើយនិម្មិតធ្វើជាគោហ្វូងខ្លះ ជាឆ្កែទាំងឡាយខ្លះ នៅក្នុងទីជិតនៃពួកពាណិជទាំងឡាយ ដើម្បីនឹងញុាំងពាណិជទាំងនោះឲ្យចូលចិត្តថា យើងរាល់គ្នាមក

បតសិណាក់នៅក្នុងទីនេះ គឺនៅជិតជាមួយនឹងលំនៅរបស់មនុស្សដូចគ្នាដែរកុំឲ្យមានសេចក្ដីរង្កៀស ។ ទើបនាងយក្ខិណីដើរចូលទៅជួបនឹងពាណិជទាំងអស់នោះ ហើយនាងទាំងនោះនិយាយបរហាទៅកាន់អ្នកឈ្មួញដោយពាក្យទន់ពីរោះជាមធុរកថា ថាតែអស់លោកអស់អ្នកគ្រប់គ្នាចូលលោកពីសាប់មរពីសាបាយនឹងម្ហូបចំណីទាំងនេះដែលយើងខ្ញុំរាល់គ្នាតាមកជូនដោយសេចក្ដីស្មោះត្រង់របស់យើង ។

ឯពាណិជទាំងឡាយនោះ ជាមនុស្សឥតមានរង្កៀសឬសង្ស័យអ្វីបន្តិចបន្តួចសោះស្មានចំពោះថាជាស្រីមនុស្សជាធម្មតាគ្មានដឹងថាជាយក្ខិណីនោះសោះឡើយ ហើយក៏ទទួលបរិភោគនូវភោជនដែលនាងយក្ខិណីនាំមកនោះទាំងអស់គ្នា ។ ឯនាងយក្ខិណីនោះក៏មានចិត្តរីករាយសប្បាយហើយធ្វើបដិសណ្ឋារទទួលដោយស្រួលបួលគ្រប់កិច្ចទាំងពួង ក្នុងវេលាដែលពាណិជទាំងនោះបរិភោគហើយសំរាកសំរានកាយនូវសេចក្ដីឆ្អែតអាហារនោះឯង ។ លុះធ្វើបដិសណ្ឋារកិច្ចរួចស្រេចហើយនាងយក្ខិណីទាំងឡាយក៏និយាយដោយវាចាដ៏ទន់ពីរោះចំពោះទៅរកពាណិជ

ទាំងឡាយនោះថា អស់អ្នកម្ចាស់ទាំងអស់គ្នានេះអ្នកទៅកាន់ប្រទេសណា អ្នកអញ្ជើញមកពីទំណា ហើយអ្នកនឹងអញ្ជើញទៅកាន់ទីណាទៀត ដែលលោកអញ្ជើញមកទីនេះតើលោកមានត្រូវការដោយកិច្ចអ្វី សូមលោកប្រាប់យើងខ្ញុំគ្រប់គ្នាឲ្យបានដឹងផង ។ បំណែកឯពួកពាណិជទាំងឡាយនោះបានទទួលស្តាប់នូវសេចក្តីសារស័ព្ទដោយសុន្ទរវាចាររបស់នាងទាំងនោះ ហើយក៏ឆ្លើយប្រាប់ត្រង់តាមសេចក្តីពិតថា នែប្អូនស្រីទាំងឡាយយើងរាល់គ្នានេះជាអ្នកជំនួញ នាំគ្នាចុះសំពៅ បញ្ចៅរកលក់ដូរតាមស្រុកដែលគួរទៅ លុះបើកសំពៅទៅដល់ទីកណ្តាលសមុទ្រ ហើយក៏ប្រទះលើព្យុះខ្យល់យ៉ាងធំបោកមកបែកសំពៅធ្លាយកណ្តាលសាគរនោះទៅ ទើបយើងរាល់គ្នាខំហែលឆ្លងកាត់មករកស្រុកនេះ សូមប្អូនស្រីទាំងឡាយបានជ្រាបដោយហេតុដូច្នេះឯង ។ ឯនាងយក្ខិណីទាំងឡាយបានស្តាប់សេចក្តីសារស័ព្ទរៀបរាប់នៃពាណិជទាំងនោះហើយក៏ឆ្លើយទៅវិញថា ឱអស់លោកទាំងឡាយលោកបានអញ្ជើញមកដល់ទីនេះជាការស្រួលពេកណាស់ ព្រោះបានប្រទះនឹងយើងខ្ញុំគ្រប់គ្នា ឯយើង

រាល់គ្នានេះក៏មិនមែនជាអ្នកស្រុកនេះដែរ  គឺជាអ្នកដំណើរបុះសំពៅមកជាមួយនឹងស្វាមីនៃយើងគ្រប់គ្នា មកនៅក្នុងស្រុកនេះប្រមាណជា ៣ ឆ្នាំហើយ  តែប្ដីយើងទាំងឡាយនោះក៏លុះមរណកាលកន្លងទៅអស់ សព្វថ្ងៃនេះយើងខ្ញុំនៅកំព្រាដោសុខតែស្រី ៗ នេះទេ ឥឡូវនេះបានប្រទះនឹងលោកអ្នកទាំងឡាយក៏ជាអ្នកកំសត់ឥតភរិយា  ហើយជាអ្នកឈ្នួញដូចស្វាមីយើងពីមុននោះដែរ  បើដូច្នេះយើងខ្ញុំទាំងអស់គ្នាសូមបង្អោនខ្លួនបួលមកធ្វើកិច្ចបំរើអ្នកជាបាទបរិចាគតាមអស់អ្នកត្រូវការប្រើប្រាះបុះ ឯពួកពាណិជទាំងអស់នោះក៏មានសេចក្ដីសោមនស្សស្នេហាប្រព្រឹត្តទៅជាមួយនឹងស្រីទាំងឡាយនោះឥតមានសង្ស័យ ។ ចំណែកនាងយក្ខិណីទាំងនោះលុះបាននិយាយលួងលោមប្រលោមនូវពាណិជទាំងអស់នោះដោយការមារយាយាងយាសរបស់ខ្លួនបានហើយក៏បបួលពាណិជទាំងនោះទៅកាន់នគរយក្ខនោះឯង ។

ម្យ៉ាងទៀតឯនាងយក្ខិណីទាំងឡាយនោះថាបើមានមនុស្សដែលខ្លួនចាប់បានហើយអំពីថ្ងៃមុននាំយកមកទុកធ្វើជាស្វាមី ក៏ចាប់ចងដាក់ប្រវាក់នូវប្ដីទាំងនោះនាំទៅទុកក្នុងផ្ទះសំរាប់សម្លាប់

ដើម្បីបរិភោគនោះទៅ ថាបើមិនមានមនុស្សឯណាដែលធ្លាយសំពៅហើយមកនៅក្នុងសំណាក់នៃខ្លួនទេ ក៏នាងយក្ខិណីទាំងនោះឆ្លងពីកោះលង្កាទៅឯកល្យាណិប្រទេសត្រើយនាយហើយត្រឡប់មកឯនាគទ្វីបវិញ ស្វែងរកមនុស្សទាំងឡាយដរាបដល់បាន ឯការដែលនាងយក្ខិណីស្វែងរកយ៉ាងនេះជាទំនៀមឬធម្មតារបស់ខ្លួនដូច្នោះ ។

អបេកទិវិសំបញ្ញសត្ថាហិន្ទនាគ ពាណិជនាសំនកុរសមិរបេខត្តិសុ ក្នុងវេលាថ្ងៃមួយនោះមានពាណិជចំនួន ៥០០ នាក់ធ្លាយសំពៅនៅក្នុងសមុទ្រ ហើយនាំគ្នាហែលឆ្លងទៅកាន់ទីជិតនៃនគរយក្ខិណីទាំងឡាយនោះ ឯនាងយក្ខិណីទាំងនោះក៏បបួលគ្នាទៅរកពាណិជទាំង៥០០នោះទៀត លុះបានជួបហើយក៏និយាយលួងលោមបញ្ចប់ពាណិជទាំងនោះ បានមកធ្វើជាស្វាមីទាំងអស់គ្រប់គ្នា ទើបបបួលពាណិជជាប្ដីថ្មីទាំងនោះទៅកាន់នគរនៃយក្ខនោះឯង ហើយនាងយក្ខិណីទាំងនោះចាប់បង់ដាក់ច្រវ៉ាក់មនុស្សទាំងឡាយ ដែលខ្លួនចាប់បានមកទុកធ្វើជាប្ដីក្នុងកាលជាន់មុននោះ រួចនាំយកទៅដាក់ក្នុងផ្ទះសំរាប់សំម្លាប់បរិ-

ភោគនោះទៅ បំណែកយក្ខិណីទាំង៥០០នាក់នោះ យក្ខិណី
ដែលជាធំជាងគេត្រូវបាននាយពាណិជដែលជាធំជាងពាណិ
ទាំងពួងនោះធ្វើជាប្តី ឯយក្ខិណីទាំងឡាយដែលសេសក្រៅ
នាងនោះត្រូវបានពាណិជឯទៀតនោះជាប្តីរៀងខ្លួនគ្រប់គ្នាទាំងអ
ឥតមានខ្វះឡើយ ។

ក្នុងវេលាមួយនោះនាងជេដ្ឋយក្ខិណី ក្រោកឡើងអំពី
ណោកក្នុងពេលដែលពាណិជជាប្តីនោះកំពុងដេកលក់ស្កប់ស្ក
ក្នុងពេលពាក់កណ្តាលអាធ្រាត្រ ហើយលបចេញទៅឯផ្ទះ
មនុស្សទុក លុះដល់ទៅទីនោះហើយក៏សម្លាប់នូវមនុស្សដែ
ខ្លួនចងទុកនោះយកសាច់មកបរិភោគជាអាហារ ឯយក្ខិណីឯ
ពីនេះក៏ធ្វើអំពើនេះដូចនាងយក្ខិណីជាធំនោះដែរ ។

ឯនាងយក្ខិណីដែលជាធំនោះកាលបើបានបរិភោគ
សាច់មនុស្សនោះហើយវេលាណាក៏មានសរីរកាយនោះត្រជ
ាក់សើមអស់ទាំងខ្លួនប្រាណ ។

បំណែកខាងនាយពាណិជនោះកាលដែលដេកជាមួយនឹ
ប្រពន់នោះមិនមែនលក់ស្កប់ស្កល់ទេ គឺគ្រាន់តែធ្វើអាការដូច

ដេកលក់មែន ឯគំនិតស្មារតីក៏ខំប្រឹងសង្កេតចាំមើលបំណាំនៃប្រពន់នោះ ព្រោះមានសេចក្ដីងឿងសង្ស័យពីថ្ងៃមុនពិចៗមក ហើយក្នុងវេលានោះក៏បានដឹងកល់ឧបាយសេចក្ដីទុច្ចរិតនៃនាងយក្ខិណីនោះប្រាកដពិតសង្ស័យទើបគិតទុកក្នុងចិត្តថា អរម្ភហ៊ិបសាយិតុំវុឌ្ឍតិ ការនេះគួរតែយើងរត់ចេញចាកទីនេះទើបសមលុះគិតដូច្នោះហើយក៏ក្រោកឡើងដើរចេញទៅរកទីកលប់មុខក្នុងវេលាព្រឹកឡើងនោះ ហើយក៏ប្រាប់ដំណើរនេះដល់ពួកពាណិជដ៏សេសទាំងអស់ឲ្យដឹងសេចក្ដីថា នែគ្នាយើងទាំងអស់ប្រពន់យើងសព្វថ្ងៃនេះមិនមែនជាមនុស្សស្ត្រីត្រឹមត្រូវសុទ្ធល្អទេ គឺជាមេយក្ខិណីទេតើ ឯនាងយក្ខិណីទាំងនេះតែវាបានមនុស្សប្រុសដ៏ទៃដែលធ្លាយសំពៅហើយធ្លងមកសំណាក់នឹងវា ៗ នឹងយកមនុស្សទាំងនោះធ្វើជាប្ដី ហើយវានឹងសម្លាប់យើងគ្រប់គ្នាទំពាស៊ីសាច់ផឹកឈាមមិនខានទេ ហេតុនេះគួរតែយើងរាល់គ្នារកឱកាសនឹងគេចរត់ចេញអំពីទីនេះទើបរស់រូបជីវិតបាន ។

បណ្ដាពាណិជទាំង ៥០០ នោះ ពាណិជ ២៥០ នាក់ជំរាបមកនាយពាណិជនោះវិញថា មយំឯតាវិជហិតុំនសក្ខិស្សាម

យើងខ្ញុំគ្រប់គ្នានេះមិនអាចនឹងលោកលែងលះបង់ចោលប្រពន្ធ
របស់យើងទាំងនេះទេ សូមលោកនាយអញ្ជើញទៅទីណា
ក៏ទៅចុះឯយើងទាំង ២៥០ នាក់នេះទៅមិនរួចទេ ព្រោះមាន
ចិត្តអាណិតស្តាយប្រពន្ធពេកណាស់ ។

ឯនាយពាណិជនោះក៏ខំនិយាយបំបួលដរាបដល់អស់កំ
នឹងនិយាយបានហើយ ក៏បបួលគ្នាតែ ២៥០ នាក់ដែលបួល
ចិត្តជឿធ្វើតាមពាក្យរបស់ខ្លួននោះរត់ចេញទៅ ។ ក្នុងសម័យ
នោះព្រះបរមពោធិសត្វយើងនេះ ទទួលព្រះអង្គក៏មកយោនយ
កំណើតកើតជាសេះវលាហកមានសរីរាវយវៈ ទាំងមូលសសុ
គ្រប់កន្លែង មានកង្ហូចដាកនៃក្អែក មានសក់ស្លូតប្រាកដស្មើ
ជាស្មៅដំណេកទន្សាយ មានឫទ្ធានុភាពអាចហោះទៅដោ
អាកាសបាន ក្នុងពេលនោះក៏ព្រះពោធិសត្វស្តេចហោះចេញអំ
ព្រៃហិមពាន្តទៅកាន់តម្ពបណ្ណិទ្វីបដើម្បីនឹងរកបរិភោគនូវព្រ
សាលីដែលកើតឯងក្នុងស្រះដែលមានក្នុងកោះនោះ លុះដ
ទៅទីនោះហើយក៏បានប្រទះឃើញពួកពាណិជទាំង ២៥០ នា
នោះកំពុងរត់ស្រែចុះស្រែឡើង ទើបពោធិសត្វពោលទៅ

មនុស្សទាំងនោះដោយសំដីជាមនុស្ស ៣ ដង ព្រោះសេចក្តី
ករុណាថា ជនបទំគន្ធគាមាអត្ថិ ជនបទំគន្ធគាមាអត្ថិ អ្នក
ណាមានប្រាថ្នាចូលចិត្តចង់ទៅកាន់ជនបទដែរឬ អ្នកណាមាន
ប្រាថ្នាចូលចិត្តចង់ទៅកាន់ជនបទដែរឬ ។ ទើបពាណិជទាំង
ឡាយនោះបានឮសំដីដូច្នោះហើយ ក៏មានចិត្តត្រេកអរជាទីបំផុត
ក្រៃពេក ក៏ដើរចូលទៅជិតហើយលើកដៃសំពះពោលថា សាមិ
មយំជនបទំគមិស្សាម បពិត្រលោកម្ចាស់ យើងខ្ញុំទាំងអស់គ្នា
នេះមានប្រាថ្នាដើម្បីនឹងទៅកាន់ជនបទឆ្ងាយ សូមលោកម្ចាស់
សង្គ្រោះយើងខ្ញុំផង ។ ទើបព្រះពោធិសត្វពោលថា បើដូច្នោះ
ចូរអ្នករាល់គ្នាឡើងមកជិះលើខ្នងរបស់ខ្ញុំនេះចុះ បណ្តាជនខ្លះក៏
ឡើងជិះដល់លើខ្នង អ្នកខ្លះបានគ្រាន់តែតោងកន្ទុយ អ្នកខ្លះ
លើកដៃសំពះហើយស្ថិតនៅក្នុងទីនោះឯង បំណែកព្រះពោធិ-
សត្វព្រះអង្គក៏ហោះយោងពាណិជទាំង ២៥០ នាក់នោះជាប
ពល់តែអស់ដោយអានុភាពនៃព្រះអង្គ ហើយនាំទៅកាន់ជន
បទដាក់ឲ្យនៅតាមទីកន្លែងនៃខ្លួនគ្រប់គ្នា ឯអង្គលោកក៏ត្រឡប់
ទៅកាន់ទីលំនៅវិញ ។

ចំណែកខាងក្រោយនោះមកនាងយក្ខិណីទាំងឡាយក៏ប្រែទះបាននូវពួកឈ្មួញដទៃទៀតមកធ្វើជាប្ដីគ្រប់គ្នាហើយក៏សម្លាប់នូវពាណិជទាំង ២៥០ ដែលសល់នៅមិនព្រមទៅជាមួយនឹងនាយពាណិជនោះយកសាច់មកបរិភោគជាអាហារអស់ទៅ ។

លំដាប់នោះព្រះបរមសាស្ដាជាគ្រូយើងទ្រង់ត្រាស់ឲ្យហៅនូវភិក្ខុទាំងឡាយឲ្យចូលមក លុះដល់មកហើយទើបទ្រង់ត្រាសធម្មទេសនាជាពាក្យដំបូន្មានចំពោះភិក្ខុទាំងឡាយនោះថា នែភិក្ខុទាំងឡាយឯពាណិជទាំង ២៥០ នាក់ ជាអ្នកលុះក្នុងអំណាចនៃសេចក្ដីស្រឡាញ់យក្ខិណីនោះក៏ដល់នូវសេចក្ដីវិនាសបាកជីវិតគ្រប់គ្នាទាំងអស់ ចំណែកខាងពាណិជដែលជាអ្នកធ្វើតាមឬប្រព្រឹត្តតាមនៃស្ដេចសេះឈ្មោះវលាហកនោះក៏បានដំកល់នៅក្នុងទីជាសុខគ្រប់គ្នា នែភិក្ខុទាំងឡាយ រឿងនេះមានឧបមាយ៉ាងណាមិញ ថាមានឧបមេយ្យដូចបរិសទ្យទាំង ៤ ពួក គឺភិក្ខុ ភិក្ខុណី ឧបាសក ឧបាសិកា បរិសទ្យពួកណា ១ ជាអ្នកមិនធ្វើតាមឱវាទនៃព្រះសម្ពុទ្ធទាំងឡាយ បរិសទ្យពួកនោះនឹងដល់នូវសេចក្ដីទុក្ខយ៉ាងធំក្នុងទីអបាយភូមទាំង ៤ នឹងទីសំរាប់ធ្វើនូវកម្ម

អាក្រក់មានបំណង៥ប្រការជាដើម បំណែកខាងបរិសទ្យពួកណា ១ ដែលបានធ្វើតាមឱវាទនៃព្រះសម្ពុទ្ធ បរិសទ្យពួកនោះនឹងបានដល់នូវទីសប្បាយ គឺមានបាននូវសម្បត្តិ ៣ ប្រការនឹងកាមាវចរសួគ៌ទាំង ៦ ស្ថាន នឹងព្រហ្មលោកទាំង ២០ ជាន់មិនខានឡើយ លុះបំណេរបរកាលទៅខាងមុខទៀតគង់នឹងបានប្រទះសោយនូវសេចក្តីសុខយ៉ាងធំជាឯកន្តបរមសុខ គឺព្រះនិព្វានមិនលែងឡើយ ព្រះអរហំសម្មាសម្ពុទ្ធព្រះអង្គទ្រង់ត្រាសធម្មទេសនាឱ្យឱវាទដល់ភិក្ខុទាំងឡាយយ៉ាងនេះហើយទើបទ្រង់ព្រោសប្រទាននូវគាថាយ៉ាងនេះតទៅទៀតថា៖

យេនកាហន្តិឱវាទំ នរាពុទ្ធេនទេសិតំ វ្យសនន្តេគមិស្សន្តិ រក្ខសិហេវវាណិជា ។ យេចកាហន្តិឱវាទំ នរាពុទ្ធេនទេសិតំ សោត្ថិម្បារំគមិស្សន្តិ វលាហេនេវវាណិជាតិ ។ សេចក្តីប្រែថា អ្នកទាំងឡាយឯណា ១ មិនអាចធ្វើតាមពាក្យឱវាទដែលព្រះសម្ពុទ្ធ ទ្រង់ត្រាសទូន្មានហើយអ្នកទាំងឡាយនោះគង់នឹងដល់នូវសេចក្តីវិនាសមិនលែងឡើយ ដូចជាពាណិជទាំងឡាយដែលរាក្សសីបញ្ឆោតទំពាស៊ីនោះឯង ។

ម្យ៉ាងទៀតអ្នកទាំងឡាយឯណា ១ ដែលជាអ្នកធ្វើតាមឱវាទដែលអ្នកប្រាជ្ញសំដែងប្រាប់ហើយ អ្នកទាំងនោះគង់នឹងដល់នូវត្រើយដ៏មានសួស្ដី គឺស្ពានបរមនិព្វានមិនខាន ដូចជាពាណិជទាំងពួងដែលព្រមទៅតាមសេះវលាហកនោះឯង ។

ព្រះបរមលោកុត្តមាចារ្យជាសាស្ដាដើមរបស់យើង ទ្រង់យិតយោងទាញយកនូវរឿងរ៉ាវអំពីមុន ៗ មកសម្ដែងប្រាប់ពល់ភិក្ខុទាំងឡាយ ហើយទ្រង់ប្រកាសនូវអរិយសច្ចកថាដរាបដល់ចប់អរិយសច្ចហើយវេលាណា ឧក្កណ្ឋិតភិក្ខុនោះក៏បានដំកល់នៅក្នុងស្រោតាបត្តិផល ឯជនទាំងឡាយដ៏ទៃខ្លះក៏បានដល់អានាគាមិផល ខ្លះបានសំរេចព្រះអរហត្តផលក្នុងវេលានេះដែរ ។

ឯពាណិជទាំង ២៥០ នាក់ ជាអ្នកជឿតាមពាក្យនៃស្ដេចសេះវលាហកនោះ ក៏បានមកជាពុទ្ធបរិសទ្យក្នុងកាលនៃឡូវនេះទាំងអស់ ឯសេះវលាហកនោះមិនគឺអ្នកឯណាឡើយ គឺអង្គព្រះតថាគតនេះឯង ។៚

ចប់វលាហកជាតក



រូបសេះពលាហកនៅប្រាសាទនាគព័ន្ធកំពស់ ៣ម៉ែ,៣៥ ថតកាលពីឆ្នាំ ១៩២៤

កាលកំពុងរៀបផ្គុំជាដំបូង



រូបសេះពលាហនៅប្រាសាទនាគព័ន្ធ ថតកាលពីឆ្នាំ១៩២៦

# អំពីសេះពលាហ

តាមសំអាងដោយល័ក្ខខ័នរបស់លោក វិកទ័រ គោលូបែហ្វ

អគ្គលេខាធិការសាលាបារាំងសេស នៅចុងបូព៌ាប្រទេស ហាណូយ

ក្រម្ការ ជុំ-ម៉ៅ ជាអ្នកតែងសេចក្ដីក្នុងព្រះរាជបណ្ណាល័យ

ប្រែមកជាភាសាខ្មែរ

( ១ – ២ )

— ១ —

ក្នុងបណ្ដាក្បាច់ចំឡាក់និងរូបចំឡាក់ទាំងប៉ុន្មាន ដែលបានរកឃើញក្នុងការស្រាវជ្រាវ គាស់កកាយនៅប្រាសាទនាគ-ព័ន្ធជាខាងកើតប្រាសាទព្រះខ័នក្នុងក្រុងអង្គរ នោះរូបដែលគួរសំគាល់ គួរសរសើរជាងគេ គឺរូបសេះបោះពលាហ ។ ការដែលប្រមូលផ្គុំនូវរូបនេះឡើងវិញ មិនអាចនឹងបានសុទ្ធដូចដើមឡើយ ព្រោះបំណែកភាគដែលសំខាន់ៗ បាត់រកមិនឃើញជាច្រើន ហើយការដែលគេខំស្រាវជ្រាវរកដោយខ្នះខ្នែងដើម្បីយក

មកធ្វើជារូបនោះ នាំមិនឲ្យសង្ឃឹមបានថានឹងបានរកឃើញនៅថ្ងៃណា ១ ក្នុងអនាគតកាលឡើយ បើទោះណាជារូបសេះនេះមានសភាពអន្តរាយនឹងខុសទំនងបែបភាពធម្មតាក្តី បើទោះណាជាថ្មដែលរបើកជាប់បេញពីគ្នា មានសភាពរិលរេបសឹកហើយពុករលួយ ឬមានមេស៊ីដោយអំណាចកប់នូវក្នុងធរណីជាយូរអង្វែងក្តី ក៏ "សេះនាគព័ន្ធ" នេះនៅមានប្រយោជន៍ដោយឡែកផ្សេងដល់យើងនូវឡើយ ហើយគួរនឹងរាប់បញ្ចូលក្នុងពួកការកសាងទាំងប៉ុន្មានដែលប្លែកជាងគេ បេញមកពីដៃកន្លាក់ខ្មែរ ។

— ២ —

អំពីរឿងរ៉ាវរូបចំឡាក់នេះ ហាក់ដូចជាមិនមានអ្វីនាំឲ្យជាទីសង្ស័យឡើយ, ព្រោះបើសង្កេតមើលទៅនឹងឃើញលេបឡើងជារឿងដែលទាញយកមកពីនិទាន១ក្នុងរឿងរបស់ព្រះពុទ្ធសាសនា រឿងនេះឯងដែលមានសេចក្តីប្រែជាភាសាឥណ្ឌាផងជាភាសាចិនផង, សម្តែងអំពីសេចក្តីស្រោបស្រង់យ៉ាងអស្ចារ្យ



[illegible]

នៃពាណិជទាំង ៥០០ អ្នក ដែលបានចេញទៅជួញតាមផ្លូវស-
មុទ្រហើយបានយកពួករាក្សសីដែលនៅក្នុងកោះ ១ ជាប់សង្វៀង
ធ្វើជាភរិយា, ពួករាក្សសីនេះសុទ្ធតែបរិភោគសាច់មនុស្សជា-
អាហារហើយឯបណ្ដាពាណិជទាំង ៥០០ អ្នកដែលបានរួចរស់
មកវិញនោះអាស្រ័យដោយសេចក្ដីសង្គ្រោះនៃព្រះពោធិសត្វ ១
ព្រះអង្គដែលមានព្រះមហាករុណា បាននិម្មិតកាយជាអស្សុត្តរ ១
ហោះទៅជួយ ។

កន្លែងដែលជាងរចនារើសយកមកធ្វើជារូបចំណាងឡើង
នោះ គឺត្រង់គ្រាសំខាន់របស់រឿងនោះឯង សេះទិព្វនេះមានជុំ-
ហិរកង្កួញជើងក្រោយហើយលោះជើងមុខទាំង ២ ទៅខាងមុខ
ហោះទៅឰដ៍អាកាសវិហាឆ្លងកាត់មហាសាគរ ហើយឯបង្គោម
មនុស្សដែលប្រតោងត្រួតលើគ្នានោះក្បាលជាប់នៅខ្លួនសេះ មាន
សណ្ឋានដូចជាប្រតោងនូវកែមទូកដែលត្រូវរលកផាត់ ។

តើជាងរចនាធ្វើចំណាងសេចក្ដីត្រង់ណា ។ ឯសេចក្ដី
ស្រោចស្រង់យ៉ាងអស្ចារ្យព្រមទាំងគោលបន្ទាប់បន្សំទាំងប៉ុន្មាន
ដែលមានធ្វើជាចំណាងនៅប្រាសាទនាគព័ន្ធ នោះមានសម្ដែង

ក្នុងនិកាយ ១ របស់ពុទ្ធសាសនា ដែលភិក្ខុសេងហ្វាយបានរៀបរៀងទុកកាលពីក្នុងរវាងគ្រិស្តសករាជ ៣០០ ឆ្នាំ(១) សេចក្តីដែលភិក្ខុសេងហ្វាយបានប្រែរៀបរៀង យើងលើកយកមកដាក់ក្នុងទីនេះតាមសេចក្តីប្រែរបស់លោក អេដ្វាឆាវ៉ាន់ ដែលមាពាំអានថា ៈ "ហើយស្តេចអស្សុត្តរក៏ឡើងទៅលើភ្នំបន្លឺនូវសំរែកថា "អ្នកណាបង់ឆ្លងសមុទ្រទៅខ្លះ" បានស្រែកដូច្នេះអស់វារៈ ៣ ដង ៗ រីពាណិជទាំងប៉ុន្មាន វេលាដែលបានឮដូច្នេះហើយក៏ត្រេកអរឥតឧបមា ទើបនិយាយនឹងគ្នាថា "យើងតែងបានឮរឿង ៗ មកថាមានសេះទិព្យ ១ តែងមានករុណាជួយស្រោបស្រង់មនុស្ស ដែលមានសេចក្តីទុក្ខភ័យ ប្រហែលជាសេះនោះឯកទេដឹង" ថាតែប៉ុណ្ណោះក៏នាំគ្នាទៅដោយសេចក្តីត្រេកអរបំពោះមុខសេះនោះ ហើយសុំឲ្យជួយស្រោចស្រង់ដោយសេចក្តីករុណា គ្រានោះអស្សុត្តរពោលចំពោះទៅនឹងពាណិជទាំងនោះថា "កាលណាអ្នកនឹងចេញទៅនោះពួករាក្សសីដែលប្រកប

---

(១) មើលសៀវភៅលោក អេដ្វា ឆាវ៉ាន់ អំពីរឿង ៥០០ និទាន ដែលស្រង់យកមកពីគម្ពីរព្រះត្រៃបិដកចិន ខ្សែ១ ទំព័រ ២២៤-២២៦ សៀវភៅនេះមានក្នុងព្រះរាជបណ្ណាល័យកម្ពុជា ។

ដោយសេចក្ដីមារយា នឹងមិនលែងពកូន (ដែលមានដោយ
អ្នក) មកបង្ហាញអ្នកឡើយ ហើយវានឹងរត់តាមអ្នក ស្រែក
ទ្ទួញយំគួរជាទីអាណិតអាសូរ, ក្នុងពួកអ្នកទាំងឡាយនេះបើជា
មានអ្នកឯណាមួយ មានសេចក្ដីអាណិតអាសូរស្រណោះ ការ
អ្វីម្យ៉ាងហើយខានទៅជាមួយនឹងខ្ញុំ ទោះជាក្រោយដែលខ្ញុំចេញ
ទៅ ពួករាក្សសីនឹងមិនលែងចាប់ដោយត្រីស្រួលឡើយ (លំ-
ពែងផ្លែ ៣) វានឹងដឹកឈាះអ្នកហើយហែកសាច់អ្នកបរិភោគ
ប៉ុន្តែបើអ្នកឯណាចិត្តរឹងចិត្តធ្ងន់ ទំហ្លឹងស្មារតីទៀតនឹងបាននោះនឹង
បានរួចខ្លួនជាប្រាកដ បើដូច្នេះអ្នកណាខ្លះដែលចង់វិលទៅស្រុក
ទេសវិញចូរតាំគ្នាឡើងជិះខ្នងខ្ញុំ តោងសក់ស្វាយខ្ញុំឬតោង
កន្ទុយខ្ញុំ ឬអោបកខ្ញុំ ហើយអ្នកឯណាដែលគ្មានកន្លែងតោង
ចូរតាំគ្នាតោងអ្នកដែលបានតោងហើយ ធ្វើដូច្នេះអ្នកនឹងបាន
រស់រួចជីវិត ហើយបានឃើញមុខអាពុកម្ដាយនឹងញាតិសន្ដាន
រាល់គ្នា"

ក្នុងសេចក្ដីប្រែជាន់ដើមនា ៗ នៃរឿងនេះ (មានរឿងរបស់
ភិក្ខុស្រេងហ្លួយជាដើម ១.) នោះមាននិយាយថាតួអស្សុត្តរពលា

ហាជារូបនិម្មិតរបស់ព្រះអនាគតពុទ្ធសាក្យមុនី លុះកន្លងឆ្ងាយមកឃើញមានក្នុងគម្ពីរដែលរចនាក្នុងគ្រាក្រោយ គេទុកដាក់សេះនេះថាជាតួបំឡែងនៃព្រះធ្យានិពោធិសត្វលោកេស្វរវិញ ហើយឯប្រាសាទនាគព័ន្ធដែលយើងបានពោលហើយ ហាក់ដូចជាធ្វើឧទ្ទិស្សថ្វាយទៅព្រះពោធិសត្វនេះ ។ ដែលគេកសាងជារូបសេះនឹងរូបមនុស្សនៅមុខទីលានប្រាសាទនាគព័ន្ធ[១] ឡើងនោះគឺច្បាស់ជាគេធ្វើដើម្បីប្រកាសនូវសេចក្ដីសង្គ្រោះរបស់ព្រះអង្គ នឹងអួតសរសើរនូវឫទ្ធិអំណាចក្នុងការជួយស្រោចស្រង់ដោយសេចក្ដីករុណានេះ ។

ឯសេចក្ដីដែលយើងលើកយកមកនិយាយខាងលើនោះ មានក្នុងគម្ពីរពួកមហាយាន ចារឹកជាអក្សរសំស្ក្រឹត ឈ្មោះគម្ពីរ ករណ្ឌវ្យូហ ឬ "របៀបរៀបបំកញ្ជើ" ពិនិត្យតាមសេចក្ដីខាងចុងនៃគម្ពីរនេះ ឃើញថាជាសេចក្ដីពោលសរសើរថ្វាយ

---

(១) មើលរឿងសម្ដែងធៀបប្រាសាទនាគព័ន្ធ ដែលលោកហ្វីណូតនឹងលោកវិកទ័រគោលូបែហ្វតែង ក្នុងប៊ុលីតាំងសាលាបារាំងសេសនៅចុងបូព៌ាប្រទេសខ្សែ ២៣ ទំព័រ ៤០១—៤០៨— រឿងនេះមានក្នុងព្រះរាជបណ្ណាល័យ ។

នូវជ័យមង្គលដល់ព្រះអវលោកិតេស្វរ ដូចមានបទនមស្សការ ថា " ឱមណិបទ្មេហុំ " ជាសំគាល់ស្រាប់ ក្នុងគម្ពីរការណ្ឌវ្យូហ មានសំម្ដែងអំពីរឿងសេះហោះ(២) ដូចសេចក្ដីខាងក្រោយនេះ ។

មានពាណិជជំទង់ម្នាក់ឈ្មោះ សីហល បានចេញភេត្រា ទៅជាមួយនឹងគ្នាជាច្រើន ដើម្បីទៅជួញស្រុកឆ្ងាយ លុះទៅដល់ជិតកោះ តាម្រទ្វីប ដែលជាទីលំនៅរបស់ពួករាក្សសី ភេត្រានោះក៏ត្រូវព្យុះយ៉ាងធំហើយក៏រលំលិចក្នុងទីនោះទៅ សីហលពាណិជក៏ហែលកាត់រលកបានដល់ទៅត្រើយ ប្រទះនឹងពួកយក្សស្រីទាំងនោះក្លែងខ្លួនជាស្រីប្រកបដោយរូបឆោមប្រិមប្រិយមកទទួលជាប្រញាប់ហើយក៏នាំយកទៅក្នុងលំនៅរបស់វាទៅ ដោយជាប់ចិត្តនឹងសេចក្ដីលំអនៃសត្រីទាំងឡាយនោះ នាយភេត្រាជំទង់ក៏មិនរួញរានឹងការតម្រេករបស់កាមគុណជាមួយនឹងស្រីម្នាក់ក្នុងពួកនោះឡើយ រីឯពាណិជឯទៀតដែលបានរួចមកដល់ត្រើយទាំងអស់គ្នាហើយបានចូលមកក្នុងស្រុក

---

(២) មើលសៀវភៅលោក ប៊ូរឡេប អំពីរឿងព្រះពុទ្ធសាសនាស្រុកកឹងបោះពុម្ពពីឆ្នាំ ១៨៤៨ ទំព័រ ២២៧ និងទំព័រតទៅ សៀវភៅនេះមាននៅក្នុងព្រះរាជបណ្ណាល័យ និងសាលាបាលី ។

ដែលមិនដែលស្គាល់នោះដែរ, ក៏យកតម្រាប់សីហលពាណិជ្ជ ទាំងអស់គ្នា ក្នុងរាត្រី ១ សីហលពាណិជ្ជបានដឹងដោយ ឫទ្ធិរបស់បង្កៀង ១ ដែលនៅក្បាលគ្រែ ថាខ្លួននៅក្នុងកណ្ដាប់ ដៃពួកពិសាចយង់ឃ្នង ហើយនឹងមរណា ក្នុងចង្កូមវានាវេលា ព្រឹកឡើងមិនខាន ក្នុងវេលានោះសីហលពាណិជ្ជបានដឹងថែម ទៀតថា ឯបណ្ដាឈ្មួញទាំងឡាយឯទៀតដែលបានចូលមក នៅក្នុងកោះនេះក្នុងគ្រាមុន ៗ ក៏សុទ្ធតែជាប់គុកពួករាក្សសីទាំង អស់ហើយវាទាញយកទៅបរិភោគតែរៀងរាល់ថ្ងៃឥតមានលោះ ឡើយ លុះបានដឹងថាគ្រោះអន្តរាយនឹងមកដិតច្បាស់ណាស់ ហើយ សីហលពាណិជ្ជក៏តាំងប្រជុំនូវពាក់ពួកមកមត់ប្ដេជ្ញានឹង រត់ទៅជាមួយគ្នា លុះទៅដល់មាត់ឆ្នេរសមុទ្រ ឃើញឯសេះ ១ មកដល់បំពោះមុខ ហើយទទួលប្ដេជ្ញាថានឹងនាំនាយពាណិជ្ជ នឹងពាក់ពួកទាំងប៉ុន្មានទៅឲ្យផុតពីកោះ ប៉ុន្តែក្នុងគ្រានោះ អស្សុត្តរបានហាមជាការដាច់ខាតថា "អ្នកឯណា ១ ដែល មានចិត្តទន់ដោយសេចក្ដីក្បួកក្បួលនៃពួករាក្សសី ហើយក្រ-ឡេកមើលទៅខាងក្រោយក្នុងវេលាដែលទៅផុតពីកោះហើយ



រឿងសេះពលាហកនៅជញ្ជាំងប្រាសាទបាយ័ន សម្តែងអំពីការស្រោចស្រង់

ពាណិជ្ជាយសំពៅ



រឿងសេះពលាហៈនៅជញ្ជាំងប្រាសាទបាយ័ន

កាលសីហលពាណិជត្រឡប់ចូលស្រុកតំណៀរវិញ

អ្នកនោះឯងនឹងបានសេចក្ដីអន្តរាយដោយគិតឧបាយនឹងកែខៃវិញបាន នឹងធ្លាក់ចុះក្នុងមហាសាគរ ហើយនឹងបានជាចំណីដល់យក្សស្រីទាំងនោះជាប្រាកដ វេលានោះពួកមិត្រភាក់សីហលពាណិជក៏ទទួលបាននឹងរត់ចេញពីកោះ ដោយសេចក្ដីសោមនស្ស ប៉ុន្តែមិនមានអ្នកឯណាមួយឡើយដែលអាចចាំសិ-ងដែលបានចោមជាប់ជាតនោះឡើយ មនុស្សទាំងអម្បាលនោះមិនអាចនឹងដឹងកល់ស្នាក់ពីបាននូវវេលាដែលឡសំណោកសោកអាល័យនៃពួករាក្សសី ដែលមកឈរព្រមគ្នានៅឆ្នេសាគរ ហើយក៏របេះ ១ ម្ដង ៗ ធ្លាក់ចុះទៅក្នុងសមុទ្រទៅ មានតែសីហលពាណិជម្នាក់ដែលបានរស់រួចពីសេចក្ដីមរណក្នុងគ្រានោះ ។

លុះត្រឡប់ចូលដល់មកក្នុងស្រុកតំណៀវិញ ពាណិជជំ-ទង់ក៏បានឡើងសោយរាជសម្បត្តិក្នុងនគរសីហលកប្បា លុះបាននូវរាជាភិសេកហើយក៏តាំងលើករពលសកលយោធាទៅប្រាំងជំណើមយកកោះតាម្រទ្វីបដើម្បីផ្សាយនូវព្រះរត្នត្រ័យក្នុងទី

នោះឯង រីឯពួករាក្សសីទាំងប៉ុន្មានដែលអប្បរាជ័យខ្លបខ្លាចនូវព្រះបស្ដា ក៏បុយទៅនៅក្នុងព្រៃ ១ កន្លែងអស់ទៅ ហើយឯកោះនោះក៏បានឈ្មោះតាំងពីនោះមក ថាជាសីហលទ្វីបវិញ គឺជាកោះរបស់សីហល (សព្វថ្ងៃហៅថាកោះលង្កា) ។ នៅទីបញ្ចប់និទានអ្នកដែលមើលនឹងបានដឹងថា ស្ដេចសីហលនោះមិនមែនអ្នកឯណាដទៃក្រៅអំពីព្រះសមណគោតមសម្មាសម្ពុទ្ធនោះឡើយ ក្នុងគ្រាដែលព្រះអង្គអន្ទោលជាតិក្នុងវដ្ដសង្សារ ហើយឯសេះអស្ចារ្យនោះគឺជាព្រះលោកេស្វរពោធិសត្វនោះឯង។

សេចក្ដីប្រែនៃករណ្ឌព្យូហៈធ្វើឲ្យឃើញនូវភាពខាងចុងនៃសេចក្ដីចំរើន ព្រោះថាគម្ពីរនេះ រឿងរ៉ាវក៏កាន់តែវៀវវាយ ដោយភ្លាត់ខ្ចាត់ខ្ចាយអស់ រីឯពេលវេលាដែលនឹងកំណត់នូវរឿងនេះ នឹងអាចទុកដាក់បានថាសេចក្ដីប្រែនេះកើតឡើងក្នុងសម័យដែលមហាយាននិកាយចាប់ផ្ដើមនឹងរីតាសអំពីស្រុកឥណ្ឌា គឺជាសម័យមុនដែលសាសនានេះ បែកខ្ចាត់ខ្ចាយដោយពេញទីពីស្រុកនា ៗ ដែលកាន់ស៊ីវ្លៃតាមក្លឹង ។

តើដោយសេចក្តីប្រែនេះឬអ្វីដែលរឿងសេះពាលាហកនេះបានស្គាល់ក្នុងស្រុកខ្មែរ. សេចក្តីនេះក៏ល្មមនឹងជឿថាដូច្នេះដែរ ពិតមែនតែជាការលំបាកនឹងរកសំអាងឲ្យជាក់ស្តែង ។

ក្នុងរឿងនេះលោកល្វីហ្វីណូត៍បានស្រង់យកជាច្រើនកន្លែងមកធៀបពិចារណាហើយវាយសេចក្តីនៃរូបចំឡាក់រឿងពុទ្ធសាសនានៅជញ្ជាំងប្រាសាទបន្ទាយឆ្មារ ។

(មានតទៅទៀត)

# ប្រស្នាធម៌

ព្រះញាណបវរិវង្ស អ៊ែម ចាងហ្វាងសាលាបាឡីជាន់ខ្ពស់នៅក្រុងភ្នំពេញ

រៀបរៀង

— ៣ —

## ទី ៣— ប្រស្នាព្រះឥន្ទស្សរស្តេចកោរព្យរាជ

រឿងនេះមានក្នុងគម្ពីបញ្ញាសជាតកបច្ឆិមភាគខ្សែ ១២

សម្តែងសេចក្តីថា ថ្ងៃមួយភិក្ខុទាំងឡាយប្រជុំគ្នាក្នុងរោងធម្មសភាគសាលា. ហើយពោលសរសើរបញ្ញាគុណព្រះសម្មាសម្ពុទ្ធថាៈអាវុសោ ម្នាលអ្នកទាំងឡាយដ៏មានអាយុ ព្រះសាស្តាចារ្យជាគ្រូនៃយើងទាំងឡាយ ព្រះអង្គមានប្រាជ្ញាច្រើន មានប្រាជ្ញាក្រាស មានប្រាជ្ញាជំនៀវឆ្លាសវៀងវៃមិនមានជឿងធ្វល់អាចញុំាងមនុស្សលោកព្រមទាំងទេវលោកឲ្យស្រើបស្រួលបាន ព្រះអង្គជាបុគ្គលគួរបូជាសក្ការនៃទេវតានឹងមនុស្សទាំងឡាយ ព្រះអង្គញុំាងសត្វទាំងឡាយឲ្យបានស្ថិតនៅក្នុងសរណា-

គមន៍ ៣ នឹងសីលទាំងឡាយ ៥ ហើយញ៉ាំងសត្វទាំងឡាយ ឲ្យស្ថិតនៅបំពោះក្នុងសោតាបត្តិមគ្គ, សកិទាគាមិមគ្គ, អនាគាមិមគ្គ, អរហត្តមគ្គ, ជាអស្ចារ្យដោយវិសេសជាងបុគ្គលដទៃ ។

គ្រានោះសម្តេចព្រះបរមគ្រូសាស្តាជាម្ចាស់ ព្រះអង្គទ្រង់ឮនូវពាក្យនៃភិក្ខុទាំងឡាយនោះ ដោយទិព្វសោតញាណ ហើយព្រះអង្គទ្រង់យាងចេញទៅអំពីគន្ធកុដិ ដោយដំណើរយាងយាសនៃព្រះពុទ្ធដ៏លំអដោយសិរីសួស្តីឧបមាពុំបាន ព្រះ-អង្គយាងទៅដល់រោងធម្មសភាគសាលា ហើយទ្រង់គង់លើពុទ្ធាសនដ៏ប្រសើរ ព្រះអង្គទ្រង់សួរពេលដ៏មាននោះបានសព្វ-គ្រប់ហើយទ្រង់មានពុទ្ធដីកាថា ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ព្រះ-តថាគតបានដោះស្រាយប្រស្នាដោយប្រាជ្ញារបស់តថាគត ទេវ-តានឹងមនុស្សទាំងឡាយបានធ្វើកិរិយាបូជាធំ ដល់ព្រះតថាគតមិនមែនតែក្នុងកាលឥឡូវនេះទេ មានតាំងតែអំពីកាលមុនមក ព្រះអង្គទ្រង់សម្តែងដូច្នេះហើយទ្រង់បញ្ឈប់ព្រះពុទ្ធដីការស្ងៀមនៅដោយតុណ្ហីភាព ។

លុះដល់ព្រះសាស្ដាជាម្ចាស់ ព្រះអង្គបានទទួលអារាធនានិមន្តភិក្ខុទាំងអម្បាលនោះ ហើយទ្រង់នាំមកនូវអតីតនិទានមកសម្ដែងថា ម្នាលភិក្ខុទាំងឡាយ នាកាលអតីតកាលកន្លងរំលងទៅយូរណាស់ហើយ មានស្ដេច ១ អង្គទ្រង់ព្រះនាមព្រះបាទកោរព្យរាជ សោយរាជសម្បត្តិក្នុងនគរមិថិលាដែនវិទេហ ព្រះអគ្គមហេសីទ្រង់ព្រះនាមសុមនទេវី ។

គ្រានោះព្រះបរមពោធិសត្វ ព្រះអង្គចុតិចុះមកអំពីតាវតឹសទេវលោក មកចាប់បដិសន្ធិក្នុងផ្ទៃនៃនាងសុមនទេវីជាអគ្គមហេសី នៃព្រះបាទកោរព្យរាជនោះ ។ ទេវបុត្តទាំង ១ ពាន់ព្រះអង្គក៏ចុតិព្រមគ្នាទាំងអស់ចាកតាវតឹសទេវលោក ទេវបុត្តខ្លះមកចាប់បដិសន្ធិក្នុងផ្ទៃនៃអមច្ចត្រកូល, ទេវបុត្តខ្លះមកចាប់បដិសន្ធិក្នុងត្រកូលនៃសេដ្ឋី ។ ចាប់ដើមតាំងពីព្រះបរមពោធិសត្វចាប់បដិសន្ធិកាលឯណា ព្រះមាតាបិតាក៏សុខសប្បាយក្សេមក្សាន្ត ពុំមានរោគាព្យាធិអ្វីឡើយក្នុងពេលនោះ ។ លុះដល់គ្រាព្រះបរមពោធិសត្វនៅក្នុងផ្ទៃព្រះមាតាគ្រប់ ១០ ខែ ពេញបរិបូណ៌ហើយ គ្រានោះសម្ដេចព្រះឥន្ទ្រាធិរាជក៏ហោះចុះ

មកស្ថិតនៅក្នុងទីជិតនៃស្ទូត្រត្រៃ វេលាពាក់កណ្ដាលអាទ្រាត្រ ហើយសួរនៅប្រស្នាទៅនឹងព្រះបាទកោរព្យរាជ ពោលជាបទព្រះគាថា ៥ សុណោហិមេ ត្វំមហារាជ ឯកោបញ្ហោអត្ថិអនុត្តិយោ ទុតិយោអត្ថិបេរិ តតិយោគភិរិស្សតិ តតិយោត្ថិនបតុត្ថោ បតុត្ថោត្ថិនបញ្ចមោ បញ្ចមោអត្ថិនឆដ្ឋោ ឆដ្ឋោបញ្ហោអត្ថិបេរិ សត្តមោគភិរិស្សតិ សត្តមោអត្ថិបញ្ហោប អដ្ឋមោបបញ្ហោនត្ថិ អដ្ឋមោអត្ថិបញ្ហោប នវមោគភិរិស្សតិ នវមោអត្ថិបញ្ហោប ទសមោបេរិនត្ថិប ទសមោអត្ថិបញ្ហោប ឯកាទសមោនភិរិស្សតិ សត្តវស្សេវសម្បត្តេ សត្តមាសសត្តទិវសេ សីឃំមេបុច្ឆិតោបញ្ហោ ។ អធិប្បាយថាបពិត្រមហារាជ ព្រះអង្គចូរស្ដាប់នូវប្រស្នានេះដូច្នេះថា ប្រស្នាមានតែ ១ មិនដែលមាន ២, មានតែ ២ មិនដែលមាន ៣, មានតែ ៣ មិនដែលមាន ៤, មានតែ ៤ មិនដែលមាន ៥, មានតែ ៥ មិនដែលមាន ៦, មានតែ ៦ មិនដែលមាន ៧, មានតែ ៧ មិនដែលមាន ៨, មានតែ ៨ មិនដែលមាន ៩, មានតែ ៩ មិនដែលមាន ១០, មានតែ ១០ មិនដែលមាន ១១ ប្រស្នាទាំង ១០ បំពួកនេះ អធិប្បាយថាដូច

ម្តេចខ្លះ ប្រស្នាដែលយើងបានសួរហើយនេះ ត្រូវព្រះអង្គពិចារណាមើលសេចក្តីអធិប្បាយជាដាច់, ដល់កន្លងទៅបាន ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ យើងនឹងត្រឡប់មកសួរមហារាជម្តងទៀត បើមហារាជបានដឹងសេចក្តីអធិប្បាយប្រស្នានេះពោលដោះស្រាយបាន ទើបព្រះអង្គនឹងបានរួចពីពិន័យ បើព្រះអង្គពុំបានដឹងសេចក្តីអធិប្បាយប្រស្នានេះទេ ពិន័យនឹងមានដល់ព្រះអង្គដោយពិត ដម្បងជាវិការនៃដែកនឹងធ្លាក់ចុះមកលើសិរសាព្រះអង្គបែកជា ៧ ភាគ ព្រះអង្គនឹងស្លាប់ពុំខានឡើយ សម្តេចព្រះអម្រិន្ទ្រាធិរាជបានពោលដូច្នេះហើយ ក៏ហោះទៅកាន់ទីវិមានព្រះអង្គវិញ ។

ឯព្រះបាទកោរព្យរាជនោះកំពុងតែទ្រង់បានស្តាប់នូវប្រស្នាទាំង ១០ បំពួកដែលព្រះឥន្ទ្រសួរដូច្នោះហើយ ក៏ភិតភ័យតក់ស្លុតតើនឡើង ១ រំពេច ហើយពិចារណាមើលសេចក្តីអធិប្បាយប្រស្នាទាំង ១០ បំពួកនោះ តាំងពីពាក់កណ្តាលរាត្រីដរាបដល់ព្រះអរុណរះឡើងភ្លឺច្បាស់ ក៏ពុំបានដឹងពុំបានឃើញនូវសេចក្តីអធិប្បាយនៃប្រស្នានោះសោះ លុះដល់

ព្រឹកឡើង ព្រះអង្គមានព្រះរាជឱង្ការហៅអាមាត្យទាំងឡាយឲ្យចូលមកជួបជុំហើយ ស្ដេចទ្រង់សួរសេចក្ដីអធិប្បាយប្រស្នាទាំង ១០ បំពួកនោះនឹងអាមាត្យទាំងអស់នោះ ឯអាមាត្យទាំងអស់នោះសូម្បីតែអាមាត្យម្នាក់ក៏ពុំអាចដឹងបានឡើយ ស្ដេចសួរនាយឃ្លាំង ៗ ក៏ពុំដឹង សួរមនុស្សទាំងឡាយដែលរក្សាគួររាជមន្ទីរ មនុស្សទាំងឡាយនោះក៏ពុំបានដឹងទៀត ព្រះបរមក្សត្រិយ៍ជាម្ចាស់ផែនដី កាលបើសួរជនទាំងនោះពុំបានដឹងដូច្នោះហើយ ព្រះអង្គក៏រឹងរិតតែតក់ស្លុតភិតភ័យរំពឹងគិតថាអញមុខជានឹងស្លាប់ដោយពិត ។

ឯស្ដេចនោះក៏មានព្រះបន្ទូលហៅនាងសុមនទេវីជាអគ្គមហេសីបានចូលមកដល់ហើយ ស្ដេចក៏សួរថា ភទ្ទេ ម្នាលនាងទេវីដ៏ចំរើន អញពុំបានដឹងនូវសេចក្ដីអធិប្បាយប្រស្នាដែលទេវតាបានសួរអញ ដូច្នេះត្រូវនាងជួយពិចារណាផងមើល ។

នាងសុមនទេវី បានស្ដាប់ព្រះបន្ទូលដូច្នេះហើយក៏ទូលតបទៅវិញថា បពិត្រព្រះសម្មតិទេព ថាបើព្រះអង្គពុំបានជ្រាប

ហើយនរណានឹងដឹង មនុស្សទាំងឡាយនឹងដោះស្រាយនូវប្រ-ស្នានៃទេវតាដូចម្ដេចនឹងបាន ។

ឯព្រះបាទកោរព្យរាជទ្រង់បានស្ដាប់ពាក្យនាងទេវីទូលដូច្នោះហើយ ព្រះអង្គមានព្រះហឫទ័យតក់ស្លុតញាប់ញ័រហើយទ្រង់ក្រោធពិរោធខ្លាំងនឹងនាងទេវីខ្លាំងពេក ដោយព្រះបិតាគិតថានាងទេវីពុំបានស្រឡាញ់ព្រះអង្គ លាន់ព្រះឱសថាអញស្លាប់ប្រសើរជាងរស់នៅ ហើយទ្រង់គិតថាបើអញនឹងស្លាប់ត្រូវសម្លាប់នាងទេវីនេះឡស្លាប់មុនអញ ទ្រង់ព្រះបិតាគិតដូច្នោះហើយមានបន្ទូលហៅនាយឃ្លាំងមកបង្គាប់ថា ម្នាលនាយឃ្លាំងអ្នកត្រូវចាប់យកនាងទេវីនេះទៅសម្លាប់ ។

បំណែកខាងនាយឃ្លាំងបានទទួលព្រះអាជ្ញាស្ដេចថានឹងនាំយកទៅសម្លាប់ដោយពិត ដល់នាំទៅដល់ផ្ទះបានសួរទោសនាងទេវីបានដឹងសព្វគ្រប់ ពុំបានសម្លាប់ព្រោះឃើញថានាងទេវីពុំមានទោសអ្វីជាទម្ងន់ ហើយបិទបាំងរក្សាទុកក្នុងផ្ទះនៃខ្លួនដោយល្អ ។

គ្រានោះព្រះនាងទេវីបានទ្រទ្រង់នូវគភ៌ ១០ ខែបរិបូណ៌

ហើយបានប្រសូតិនូវព្រះរាជបុត្រា ១ ក្នុងថ្ងៃជាខាងក្រោយប្រកបដោយឧត្តរាសាឍ្ហ នក្ខត្តឫក្ស ដ៏ប្រសើរ ។ ឯកុមារនោះសោតបានប្រសូតិចេញអំពីផ្ទៃព្រះមាតាហើយមានពណ៌សម្បុរល្អបីដូចមាសដ៏វិសេសឥតមានមន្ទិលសៅហ្មងឡើយ ។

ឯនាយឃ្លាំងបានឃើញនូវព្រះរាជកុមារជាអស្ចារ្យដូច្នោះហើយ ក៏ដល់នូវសេចក្តីសោមនស្សជ្រះថ្លា ប្រកបដោយសេចក្តីស្នេហាស្រឡាញ់ពេញចិត្ត បីដូចជាកូនបង្កើតរបស់ខ្លួន ទំរំបីរចាំបិញ្ចឹមរក្សានូវនាងទេវីនិងកុមារនោះដោយប្រពៃ ។

ចំណែកឯទេវបុត្រទាំង ១ ពាន់ដែលចាប់បដិសន្ធិក្នុងត្រកូលនៃអាមាត្យនិងត្រកូលនៃសេដ្ឋីនោះ ក៏ប្រសូតិព្រមគ្នាទាំងអស់ក្នុងថ្ងៃជាមួយគ្នានឹងព្រះពោធិសត្វនោះឯង ។ នាងសុមនទេវីជាព្រះមាតាបានឲ្យនាមឈ្មោះកុមារនោះហៅថា ភណ្ឌាគារិកកុមារ ។

លុះដល់កុមារនោះចំរើនធំឡើងមានអាយុ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃគត់បរិបូណ៌ហើយ កាលនោះសម្តេចព្រះឥន្ទ្រាធិរាជក៏ហោះចុះមកអំពីស្ថានទេវលោកហើយស្ថិតនៅខាងក្រោមស្វេត្រ-

ធត្រពាក់កណ្ដាលរាត្រី ហើយសួរប្រស្នានេះនឹងព្រះបាទកេ
រព្យរាជថាមហារាជប្រស្នាដែលយើងបានសួរព្រះអង្គពីមុននេ
ព្រះអង្គបានពិចារណាដឹងសេចក្ដីអធិប្បាយហើយឬនៅ បើព្រ
អង្គមិនដឹងទេ យើងនឹងប្រហារក្បាលព្រះអង្គឲ្យបែកជា ៧ ភា
ព្រះឥន្ទ្រាធិរាជពោលដូច្នេះហើយក៏ហោះទៅកាន់ស្ថានសួគ៌ទេ
លោកនាយវិញ ។

ព្រះបាទកោរព្យរាជ ស្ដាប់នូវពាក្យព្រះឥន្ទ្រហើយភិតភ័
ញាប់រន្ធត់ក្រោកឡើងគង់ហើយរំពឹងគិតថាទេវរាជនេះសួរប្រស្
នឹងអញកន្លងទៅបាន ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ហើយអញ
បានដឹងនូវសេចក្ដីអធិប្បាយនៃប្រស្នានោះសោះ អញបានសួ
នូវអ្នកប្រាជ្ញទាំងឡាយមានអាមាត្យជាដើម គ្មាននរណាមួយ
បានដឹងសោះ ស្ដេចទ្រង់គិតដូច្នោះហើយ ក៏ដល់នូវសេចក្ដីទុ
លំបាកព្រួយព្រះទ័យយ៉ាងធំ ។

លុះដល់ព្រឹកឡើងហើយ ស្ដេចលាងព្រះកេសលុបព្រ
ភក្ត្រហើយទ្រង់ព្រះពស្ត្រសោយព្រះស្ងោយរួចហើយប្រដាប់ព្រ
អង្គដោយគ្រឿងអលង្ការទាំងពួង ហើយយាងទៅគង់កណ្ដាល

ងមហាវិនិច្ឆ័យជនទាំងឡាយទាំងអស់មានអាមាត្យធំ ៗ ជា ងើម ក៏ផ្អើលគឹកកងជ្រួលជ្រើម ចូលទៅប្រជុំខាន់ខាប់ក្នុងទី នោះ លុតជង្គង់ថ្វាយបង្គំស្តេចហើយអង្គុយនៅស្ងៀមពុំបាន ពោលថាអ្វីឡើយ ។

ព្រះបាទកោរព្យរាជ មានព្រះរាជឱង្ការសួរទៅនាយឃ្លាំង ពោលជាបទព្រះគាថា ដូច្នេះថា ៈ

ភណ្ឌាគារិកមេនាយ៉ោ  ធគរេបុលេអសិ
តុវំមហាបុញ្ញកុលេ  ញត្វាជាតោកុសលោប
បណ្ឌិតោបភវិស្សតិ  វជ្ជំភាសុវណ្ណាភា
មុតាវេទុរិយាមណី  នារិយោសមលង្កតា
សតំហត្ថីសតំអស្សា  សតំរថាសតំគាវី
សុវណ្ណសតសហស្សំ  អឌ្ឍរដ្ឋំទទាមិតេ ។

អធិប្បាយថា ម្នាលនាយឃ្លាំងអ្នកឯងជាទីពឹងនៃអញ ឲ្យដឹងនូវបុគ្គលដែលកើតក្នុងត្រកូលដែលមានបុណ្យធំមានក្នុង នគរដ៏ធំទូលាយនេះ បុគ្គលដែលកើតហើយនោះបានជាបុគ្គល ឆ្លាតវៀងវៃខ្លះ ជាអ្នកប្រាជ្ញខ្លះ នឹងមានដោយពិត បើអ្នក

ស្វែងរកអ្នកប្រាជ្ញបាន អញឲ្យនូវរង្វាន់គឺប្រាក់ខ្លះ មាសខ្លះ កែវមុក្តា, កែវវេទូរិយ៍, កែវមណី, នាងនារីប្រដាប់ស្អិតស្អាងដោយប្រពៃ, ដំរី ១ រយ, សេះ ១ រយ, រថ ១ រយ, គោ ១ រយ, មាស ១ សែន, រាជសម្បត្តិពាក់កណ្តាលដល់អ្នកដោយពិត ។

ឯនាយឃ្លាំងបានស្តាប់ព្រះរាជឱង្ការហើយ ពោលជាបទព្រះគាថាដូច្នេះថា :

គេហស្មឹឥត្ថីមយ្ហំបិ ឯកបុត្តោសុរូបតិ
ទិស្វានជាយបុត្តញ្ច កុសលោហោតិបណ្ឌិតោ
និក្ខមិមាតុយាគព្ភា នក្ខត្តេសុវិសេសុ
បស្សិមេវបណ្ឌិតោប អង្គបច្ចង្គសម្បន្នោ
រូបវណ្ណោសុលក្ខណោ ។

អធិប្បាយថា បពិត្រព្រះសម្មតិទេព សត្រីនូវក្នុងផ្ទះខ្ញុំមានរូបល្អមានកូនតែមួយ ព្រោះខ្ញុំបានឃើញនូវកូនកាលកើតឡើង ក្នុងថ្ងៃទាំងឡាយប្រកបដោយនក្ខត្តឫក្សដ៏ប្រសើរ កូននោះចេញពីផ្ទៃមាតាមានរូបឆោមលោមពណ៌ល្អ គួរជាបុគ្គលឆ្លាតវៀងវៃ ជាអ្នកប្រាជ្ញដោយពិត ខ្ញុំបានឃើញហើយគិតថាកុ

មានសីលបរិបូណ៌ដោយអរិយទ្រព្យនឹងអរិយវធិយ៉ាងនេះ មានរូបល្អមានលក្ខណនឹងវេទ ជាអគ្គបណ្ឌិតជាអ្នកប្រាជ្ញធំដ៏ប្រសើរ ។

ព្រះបាទកោរព្យរាជ ព្រះអង្គស្តាប់នូវពាក្យនាយឃ្លាំងក្រាបទូលដូច្នោះ ស្តេចមានព្រះទ័យសោមនស្សជ្រះថ្លា ហើយត្រាស់បង្គាប់ទៅនាយឃ្លាំង ថាអ្នកត្រូវទៅសួរកូននោះបើកូននោះអាចដោះស្រាយប្រស្នានៃទេវតានោះបាន ត្រូវអ្នកត្រឡប់មកប្រាប់អញវិញឲ្យឆាប់ ។ នាយឃ្លាំងលុតជង្គង់ថ្វាយបង្គំលាព្រះបាទកោរព្យរាជហើយដើរទៅកាន់ផ្ទះដោយរហ័ស ' សួរនូវបិយបុត្តរូបសំឡាញ់ពេញចិត្ត សូត្រជាបទព្រះគាថា ដូច្នេះថា

តាតបុត្តអយំរាជា មហាទុក្ខាភិស្បតិ
សក្កនបុច្ឆិតំបញ្ហំ សោនជាតាតិរាជាមំ
បហិណិត្វានអាគតោ តវបុច្ឆិតុំតាតបុត្ត
ញត្វាតំបិមេអាចិក្ខ ។

អធិប្បាយថា ម្នាលកូនសំឡាញ់ឪពុក ស្តេចនោះព្រះ-អង្គដល់នូវសេចក្តីទុក្ខធំណាស់ ស្តេចនោះព្រះអង្គពុំបានជ្រាបនូវប្រស្នាដែលព្រះឥន្ទ្រសួរនោះទេ ព្រះអង្គបញ្ជូនបិតាឲ្យមក

ដើម្បីសួរនូវសេចក្ដីអធិប្បាយនៃប្រស្នានោះនឹងអ្នក ម្នាលកូនស្ងួនឪពុក បើអ្នកពិចារណាហើយបានដឹងនូវប្រស្នានៃទេវតានោះ ចូរកូនអ្នកប្រាប់ដល់បិតា ៗ នឹងយកសេចក្ដីនេះក្រាបទូលដល់សម្ដេចព្រះមហិស្សរាធិប្ដីជាម្ចាស់ ឯព្រះបរមពោធិសត្វបានស្ដាប់ពាក្យបិតា ហើយដល់នូវសេចក្ដីសោមនស្សជ្រះថ្លា បានពិចារណានូវប្រស្នាដែលព្រះឥន្ទ្រសួរនោះ បានដឹងនូវសេចក្ដីអធិប្បាយនៃប្រស្នានោះមួយរំពេច ហើយពោលថា តាតបពិត្របិតា ខ្ញុំបានដឹងច្បាស់នូវប្រស្នាដ៏សុខុមនេះដោយសេចក្ដីសព្វគ្រប់ហើយ ។

នាយឃ្លាំងបានស្ដាប់ពាក្យបិយបុត្តពោលដូច្នោះហើយក៏មានចិត្តត្រេកអរហើយពោលថា បិយបុត្ត ម្នាលកូនសំឡាញ់ឪពុក ពាក្យដែលអ្នកពោលមកនេះប្រពៃណាស់ហើយ ។

ឯព្រះមាតានៃពោធិសត្វ ពោលទៅនឹងបុត្រថា តាតបិយបុត្តក ម្នាលកូនតូចសំឡាញ់មាសម្ដាយ ខ្លួនអ្នកនៅក្មេងណាស់ក្រែងអ្នកពុំបានដឹងទេឬ ថាបើអ្នកពុំបានដឹងហើយ

ព្រះបាទកោរព្យរាជនេះតែខ្វល់ហើយ ភ័យអន្តរាយគាប្បីមានដល់អ្នកពុំខាន ។

ព្រះពោធិសត្វបានស្តាប់ពាក្យមាតា ហើយពោលតបទៅនឹងមាតាវិញថា អម្ម បពិត្រអ្នកមេ សេចក្តីនេះខ្ញុំបានដឹងសព្វគ្រប់ហើយ ។

គ្រានោះព្រះនាងទេវីជាមាតា បានស្តាប់ពាក្យបុត្តពោលដូច្នោះហើយ ក៏ពោលថា ម្នាលកូនសំឡាញ់មាតា បើអ្នកបានដឹងសព្វគ្រប់ដូច្នេះ ប្រពៃណាស់កូន ។

ឯព្រះពោធិសត្វបានពោលទៅនឹងនាយឃ្លាំង ជាព្រះបិតាធម៌ថា តាត បពិតព្រះបិតា សូមបិតាចូលទៅកាន់សំណាក់ស្តេចហើយក្រាបទូលថា ទេវ បពិត្រព្រះសម្មតិទេព កូនរបស់ខ្ញុំបានដឹងនូវប្រស្នា ដែលព្រះឥន្ទសួរនេះដោយសព្វគ្រប់ ។

នាយឃ្លាំងបានស្តាប់ពាក្យបិយបុត្តហើយពោលថា តាតបិយបុត្តក ម្នាលកូនតូចសំឡាញ់មាសឪពុក ពាក្យដែលអ្នកបានពោលមកនេះប្រពៃហើយ ៗ ចូលទៅកាន់សំណាក់ព្រះបាទ

កោរព្យរាជយកសេចក្ដីក្រាបទូលថា ទេវ បពិត្រព្រះសម្មតិទេពកូនខ្ញុំបានដឹងនូវសេចក្ដីអធិប្បាយនៃប្រស្នាដែលព្រះឥន្ទសួរហើយនោះដោយជាក់ច្បាស់ ។

ព្រះបាទកោរព្យរាជ ទ្រង់បានស្ដាប់ពាក្យនាយឃ្លាំងក្រាបទូលដូច្នោះហើយ ទ្រង់មានព្រះហឫទ័យជ្រះថ្លា ហើយមានព្រះរាជឱង្ការបង្គាប់ថា ម្នាលនាយឃ្លាំង ពាក្យនេះប្រពៃហើយ កូនអ្នកចេះដឹងនូវប្រស្នានោះពិតមែន បើដូច្នេះត្រូវអ្នកញាំងកូនតូចនោះឲ្យងូតទឹកជំរះញើសក្អែល ហើយឲ្យស្លៀកសំពត់ស្អិតស្អាងដោយគ្រឿងប្រដាប់ទាំងពួង ឲ្យបរិភោគនូវភោជនាហារទាំងពួងហើយចូរនាំចូលមកកាន់សំណាក់អញជាឆាប់ ហើយស្ដេចបញ្ជូននាយឃ្លាំងនោះទៅ ។

ឯនាយឃ្លាំងបានទទួលព្រះរាជឱង្ការត្រាស់បង្គាប់ដូច្នោះហើយ ក៏ថ្វាយបង្គំលាចេញទៅកាន់ផ្ទះខ្លួនដោយឆាប់ ហើយប្រាប់កូនតូចថា ម្នាលកូនតូចសំឡាញ់ឪពុក ព្រះនរិន្ទ្រាធិបតីជាម្ចាស់ ព្រះអង្គមានប្រាថ្នាដើម្បីឃើញអ្នក ហើយបញ្ជូនបិតាមកឲ្យនាំអ្នកចូលទៅគាល់ ឥឡូវនេះ ។

ព្រះពោធិសត្វ ស្តាប់ពាក្យបិតាពោលដូច្នោះហើយពោល តបវិញថា សាធុ ៗ បពិត្របិតា បើដូច្នោះ សូមបិតាចូលទៅ ក្រាបទូលដល់ព្រះបាទកោរព្យរាជ តាមពាក្យខ្ញុំដូច្នេះថាបើ ស្តេចសព្វព្រះទ័យ នឹងឲ្យខ្ញុំចូលទៅគាល់ សូមស្តេចចាត់ចែង រាជអាមាត្យ ឲ្យរៀបក្រាលអាសនទាំងឡាយក្នុងព្រះដំណាក់ ស្តេច ហើយបូជាខ្ញុំដោយផ្កាលាជដ៏លំអដោយសិរីនឹងបូជា ដោយគ្រឿងក្រអូបនឹងគ្រឿងលាភនឹងធូបប្រទីបទាំងឡាយ ហើយចងនូវពិតាននឹងលើកឡើងនូវស្វេត្រឆត្រនឹងទង់មាស ទង់ប្រាក់ ហើយបោសសំអាតក្នុងប្រាសាទឲ្យស្អាតល្អ ហើយ ក្រាលនូវសំពត់ពណ៌ខៀវនឹងពណ៌ក្រហមជាដើម ហើយប្រជុំ នូវអ្នកនគរទាំងអស់ នឹងប្រជុំនូវអាមាត្យទាំងអស់ ប្រគំនូវ ភ្លេងតូរ្យតន្ត្រីប្រកបដោយអង្គប្រាំ មហាជនទាំងឡាយទាំងពួង ប្រជុំគ្នាព្រមហើយធ្វើនូវមង្គល មានសំពត់នឹងគ្រឿងអម្ពរស្លៀក ពាក់ដ៏ស្អាតល្អ ហើយចូលទៅចាំជង្ហែខ្ញុំមក ឯខ្លួនខ្ញុំស្ថិត នៅលើយានដំរីប្រកបដោយស្វេត្រឆត្រ គឺពួកមហាជននឹង

អាមាត្យ ហោមរោមហើយនឹងចូលទៅកាន់សំណាក់ព្រះរាជនេត្រ ជាម្ចាស់ ។

ឯនាយឃ្លាំងបានស្ដាប់ពាក្យបិយបុត្តពោលបង្គាប់ដូច្នោះ ហើយទទួលថាសាធុ ហើយក៏ចូលទៅក្រាបបង្គំទូលដល់ សម្ដេចព្រះភូវនាថតាមពាក្យបង្គាប់ព្រះពោធិសត្វដោយសព្វ គ្រប់ ។

លំដាប់នោះសម្ដេចព្រះភូមិន្ទនរិន្ទ្រាធិបតី ទ្រង់បាន ស្ដាប់នូវពាក្យនាយឃ្លាំងក្រាបទូលតាមពាក្យកុមារនោះហើយ ទ្រង់មានព្រះរាជហឫទ័យត្រេកអរជ្រះថ្លាត្រាស់បង្គាប់រាជអាមាត្យ ឲ្យរៀបរណ្ដាប់តាក់តែងចាត់ការតាមបង្គាប់ព្រះពោធិសត្វដោយ សព្វគ្រប់ ។

ឯជន់ទាំងឡាយមានអាមាត្យជាដើម បានធ្វើតាមបង្គាប់ ព្រះនរាធិបតីស្រេចហើយ ប្រដាប់នូវដំរីមួយប្រកបដោយគ្រឿង ប្រដាប់សុទ្ធតែមាសនឹងកែវផ្សេង ៗ ហើយទទ្រង់នូវស្វេត ឆត្រ នាំទៅដើម្បីជាមង្គលឲ្យកុមារឡើងគង់នឹងដង្ហែចូលមក កាន់សម្នាក់ព្រះមហាក្សត្រិយ៍ ។

បណ្ដាជន់ទាំងអស់នោះមានរាជាមាត្យជាដើម សឹងតែប្រដាប់ស្អិតស្អាងអាត្មាទីទៃ ៗ ហើយចូលទៅកាន់ផ្ទះព្រះបរមពោធិសត្វ ធ្វើនូវកិរិយាបូជាហើយពោលថា សាមិ បពិត្រកុមារជាម្ចាស់ ឥឡូវនេះព្រះបាទកោរព្យរាជ ស្ដេចប្រើយើងទាំងឡាយ ឲ្យមកអញ្ជើញកុមារចូលទៅកាន់សម្នាក់ព្រះអង្គពោលដូច្នេះហើយ លើកឡើងនូវអញ្ជលីប្រណម្យនមស្ការ ដើម្បីនឹងញាំងព្រះពោធិសត្វឲ្យព្រះហ្ឫ ហើយពោលថា សាមិកាលោភោគមនាយ បពិត្រកុមារជាម្ចាស់ កាលនេះជាកាលគួរដល់ព្រះអង្គហើយ ដើម្បីកិរិយាទៅកាន់សម្នាក់ព្រះបមបូរីជាម្ចាស់ជីវិត ។

គ្រានោះព្រះមហាសត្វ បានទទួលព្រមតាមពាក្យមហាជន់ទាំងអម្បាលនោះថាសាធុ ៗ ហើយប្រដាប់ព្រះអង្គដោយគ្រឿងអលង្ការទាំងពួង ស្រេចហើយថ្វាយបង្គំលាព្រះមាតាយាងចុះអំពីផ្ទៃប្រាសាទដ៏ប្រសើរ បីដូចជាទេវរាជចុះចាកវិមានទិព្យ គឺពពួកអាមាត្យទាំងឡាយហោមរោមជាបរិវារ ហើយប្រគំឡើងព្រមនូវភ្លេងតូរ្យតន្ត្រីទាំងពួង ។

ឯសេនាប្រកបដោយអង្គ ៤ គឺសេនាដំរី សេនាសេះ សេនារថ សេនាថ្មើរជើង ក៏ដើរដង្ហែទៅក្នុងខាងមុខព្រះបរមពោធិសត្វ អមផ្លូវទាំងសង្ខាង ។

រីព្រះបរមពោធិសត្វ ក៏ឡើងគង់លើក្បួនដំរីដ៏ប្រសើរដ៏មានរូបឆោមលោមពណ៌ដ៏ល្អវិសេស្ស បីដូចជារូបព្រៀបជាវិការនៃមាសសុទ្ធ គឺមហាជនព្រមទាំងសេវកាមាត្យ ដង្ហែចូលទៅកាន់ព្រះបរមរាជវាំងស្តេច ប្រកបដោយសិរីសួស្តីឧបមាពុំបាន។

កាលនោះព្រះជនាធិបតីកោរព្យរាជ កាលព្រះអង្គរមិលមើលនូវផ្លូវនៃ ភណ្ឌាគារិកកុមារនោះ ពុំអស់ពុំកើយបីដូចជាអ្នកលេងផឹកសុរា មានសេចក្តីស្រេកចង់ផឹកជានិច្ច ព្រះអង្គរមិលមើលផ្លូវដែលជាទីមក នៃបរមពោធិសត្វនោះពុំដាក់ព្រះនេត្រសោះ លុះស្តេចបានឮសំឡេងខ្លាំងហើយទតទៅឃើញកុមារដ៏មានពន្លឺរស្មីរុងរឿងល្អ ហើយពោលពណ៌នាដោយបទព្រះគាថាដូច្នេះថា ។

កស្សេតំមុខមាភាតិ ហេមវុត្តត្តមគ្គិនា
និក្ខំវជាតរូបស្ស ឧក្កាមុខំបហំសិតំ

និសិន្នោហត្ថិខន្ធេ បតិមារីយសោភតិ

អធិប្បាយថា មុខនេះជាមុខនៃបុគ្គលដូចម្តេចមានខនបី-ប្រជាមាស គឺបុគ្គលជិតហើយដោយភ្លើងដ៏ភ្លឺរុងរឿងបីដូចផ្កានៃមាសគឺបុគ្គលឡើងជិះហើយដកចេញអំពីមាត់នៃបាវមាសភ្លឺរុងរឿងល្អ កុមារនេះអង្គុយនៅលើកន្លនៃដំរីរុងរឿងល្អបីដូចរូបទៀបនៃមាស ។

គ្រានោះព្រះបរមពោធិសត្វ បានដល់ទ្វាររាំងហើយចុះអំពីកន្លនៃដំរី ចូលទៅកាន់សំណាក់ព្រះមហាក្សត្រ ៗ ចាប់ដៃព្រះបរមពោធិសត្វនាំឡើងទៅលើប្រាសាទហើយស្តេចគង់នៅលើអាសនមួយ ជាមួយនឹងព្រះពោធិសត្វហើយស្តេចពោល សារាណីយកថា ជាពាក្យបដិសណ្ឋារដោយបទព្រះគាថាដូច្នេះថាៈ

កច្ចិអមជ្ជបោតាត កច្ចិតេសុរមប្បិយំ
អហោសច្ចេចធម្មេច ទានេតេរមតីមនោ

អធិប្បាយថា ម្នាលអ្នក ៗ មិនបានផឹកនូវទឹកស្រវឹងទេឬសុរាមិនជាទីស្រឡាញ់នៃអ្នកទេឬ ម្យ៉ាងវិញទៀតចិត្តអ្នកត្រេកអរក្នុងពាក្យសច្ចក្នុងធម៌ក្នុងទានដែរឬ ។

បំណែកខាងព្រះបរមពោធិសត្វស្តាប់ហើយពោលដោយបទព្រះគាថា ដូច្នេះថា ៕

អមជ្ឈបោ ហាហំរាជ អហោមេសុរមប្បិយំ
អហោសច្ចេបធម្មេប ទានេមេរម្មតីមនោ

អធិប្បាយថា បពិត្រមហារាជ ខ្ញុំព្រះអង្គពុំបានផឹកនូវទឹកស្រវឹងទេ ម្យ៉ាងវិញទៀតសុរាមិនជាទីស្រឡាញ់នៃខ្ញុំទេ ម្យ៉ាងវិញទៀតចិត្តខ្ញុំត្រេកអរតែក្នុងពាក្យសច្ចក្នុងធម៌ក្នុងទានជាប្រក្រតី ៕

លុះដល់ព្រះមហាសត្វ ធ្វើបដិសណ្ឋារដូច្នេះហើយ ក៏ក្រាបទូលសួរទោសសម្តេចព្រះភូមេសរ៍កោរព្យរាជថា មហារាជបពិត្រស្តេចដ៏ប្រសើរ ទេវតាបានសួរប្រស្នានឹងព្រះអង្គដូបម្តេចខ្លះ ៕

តំសុត្វារាជា សម្តេចព្រះភូមេសរ៍ស្តេចបានទ្រង់ព្រះសណ្តាប់ពាក្យព្រះបរមពោធិសត្វទូលសួរដូច្នោះហើយ ព្រះអង្គមានបន្ទូលថា តាតកុមារ ម្នាលកុមារអ្នក ទេវតាសួរប្រស្នានឹងអញដោយអាការ ១០ យ៉ាង ប្រស្នានោះគ្មានអ្នកឯណាមួយដឹងឡើយព្រោះហេតុដូច្នោះ អញដល់នូវសេចក្តីទុក្ខលំបាកធំ

ព្រះឥន្ទ្រាធិរាជគប្បីបហារក្បាលអញដោយដំបងដែកឲ្យបែកជាភាគ ៧ ចាប់ដើមអំពីកាលនៃប្រស្នាដែលព្រះឥន្ទសួរហើយមកដល់ឥឡូវនេះ កន្លងទៅបាន ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃហើយ ឥឡូវនេះអ្នកគឺអញបាន់ហើយត្រូវអ្នកដោះស្រាយប្រស្នានេះឲ្យឆាប់ ។

ព្រះបរមពោធិសត្វនោះ ស្ដាប់ហើយទូលថា បពិត្រស្ដេចធំដ៏ប្រសើរ ប្រស្នានោះលើកទុកសិនចុះ ខាងក្រោមតាំងអំពីនរកឈ្មោះអវិចីមកខាងលើតាំងអំពីអកនិដ្ឋព្រហ្មចុះមក ហើយសួរប្រស្នាឯណា ទុំអាចនឹងសំដែងនូវប្រស្នានោះបានទាំងអស់ពុំមានសល់ ព្រះបរមពោធិសត្វសំដែងនូវប្រាជ្ញាព្រះអង្គដ៏ធំទូលាយដូចភ្នំព្រះសិនេរុ ពុំនោះសោតបីដូចជាព្រះចន្ទពេញបូរមីមានប្រការផ្សេង ៗ ។

បណ្ដាអស់ទេវតានឹងមនុស្សទាំងឡាយ ព្រមទាំងនាងកញ្ញានឹងពពួក ពលសកលយោធានូវសេវកាមាត្យទាំងអស់ ក៏បង្កើតជាអស្ចារ្យដ៏ក្រៃលែងទាំងខាងក្នុងនឹងខាងក្រៅប្រាសាទនៃព្រះបាទកោរព្យរាជនោះ ។

ព្រះមហាសត្វកាលសំដែងនូវបញ្ញានុភាពនៃព្រះអង្គហើយ ពោលជាបទព្រះគាថាដូច្នេះថា ។

ភោន្តោភោន្តោទេវសំឃា   សុណន្តុវចនំមម
ទេវតាបុច្ឆិតបញ្ហំ   រាជាអត្ថំនបស្សតិ
សមាគតាទេវសំឃា   មោទិតាចមហាជនា
កោរព្យញ្ចអមច្ចេច   សេនាបតិបអាទយោ
តស្មិំបញ្ហោវិសជ្ជេន្តេ   តុដ្ឋុការភវន្តុមេ ។

BIBLIOTHÈQUE FRANÇAISE D'EXTRÊME ORIENT

អធិប្បាយថា បពិត្រពពួកនៃទេវតាទាំងឡាយដ៏ចំរើណ ចូរស្តាប់នូវពាក្យនៃខ្ញុំ ដ្បិតទេវតាសួរប្រស្នានឹងស្តេច ៗ ពុំបានឃើញនូវសេចក្តីអធិប្បាយនៃប្រស្នានោះ ទេវតាទាំងឡាយក៏មកប្រជុំគ្នា ហើយមហាជនទាំងឡាយក៏បានរីករាយហើយ ព្រោះអាស្រ័យនូវស្តេចផង នូវអាមាត្យទាំងឡាយមានសេនាបតីជាដើមផង នាកាលប្រស្នានោះកាលបើខ្ញុំបានដោះស្រាយហើយ សាធុការទាំងឡាយសូមបង្កើតមានដល់ខ្ញុំដោយពិត ៗ លុះដល់ព្រះបរមពោធិសត្វបានប្រកាសដល់ទេវតាស្រេចហើយ ក៏ក្រាបទូលសួរទៅព្រះចមនគរមិថិលាជាម្ចាស់ថា មហារាជ

បពិត្រព្រះអង្គជាបុគ្គលត្រេកអរទៅក្នុងផែនដី ប្រស្នាជាបឋម ដែលសម្តេចសហស្សនេត្របានសួរព្រះអង្គនោះតើដូចម្តេច ។

ឯព្រះចៅធនីកោរព្យរាជ ទ្រង់ស្តាប់ដូច្នោះហើយមានព្រះបន្ទូលថា ម្នាលបាជាកុមារតូច ទេវតាបានសួរប្រស្នាជាបឋម នោះថា ឯកោអត្ថិ អទុតិយោ សភាវមានតែមួយពុំដែលមានពីរគឺសភាវអ្វី ។

ព្រះពោធិវង្សបានស្តាប់ហើយបានជ្រាបអធិប្បាយមួយរំពេច ទូលថាបពិត្រមហារាជ សូមព្រះអង្គទ្រង់ស្តាប់នូវពាក្យខ្ញុំ ឯសភាវមានតែមួយពុំដែលមានពីរនោះគឺភ្នំព្រះសុមេរុ ព្រោះក្នុងលោកនេះកណ្តាប់បក្កវាឡមួយមានភ្នំសិនេរុតែមួយជាធម្មតាពុំមានសភាវអ្វីជាគំរប់ពីរឡើយសូមព្រះអង្គទ្រង់ជ្រាប ។

គ្រានោះព្រះបមទិញាធិបតីជាស្តេចទេវតា ទ្រង់ស្តាប់នូវពាក្យវិសជ្ជនានូវប្រស្នានៃព្រះបរមពោធិសត្វនោះហើយ ទ្រង់ផល់នូវសេចក្តីសោមនស្សមានព្រះទ័យបង្កើតជាអស្ចារ្យ ហើយដោះនូវសំពត់នឹងគ្រឿងអម្ពរ បូជាព្រះពោធិសត្វ ឲ្យនូវ

ស័ព្ទសាធុការហើយប្រស់ព្រំនូវទឹកក្រអូបដ៏ជាទិព្យដល់ព្រះពោធិសត្វ ។

ឯទេវតានឹងមនុស្សទាំងឡាយព្រមទាំងព្រះនរបតីកោរព្យរាជនូវសេវការមាត្យទាំងអស់ បានស្តាប់នូវពាក្យបញ្ហាវិសជ្ជនានៃភណ្ឌាគារិកកុមារនោះហើយ ក៏សឹងដល់នូវសេចក្តីសោមនស្សព្រឺព្រួចលោមាបង្កើតជាអស្ចារ្យក្នុងចិត្តរាល់ ៗ គ្នាដោះនូវសំពត់នឹងគ្រឿងអម្ពរធ្វើជាធម្មបូជាដល់ព្រះមហាសត្វហើយពោលសរសើរថា កុមារក្មេងតូចនេះទើបតែនឹងបានអាយុ ៧ ឆ្នាំទេមានប្រាជ្ញាអ្វីច្រើនជាអស្ចារ្យដល់ម្លេះ ។

បំណែកឯព្រះបរមពោធិសត្វ ក៏ទូលសួរទៅព្រះមហាក្សត្រទៀតថា បពិត្រមហារាជ ប្រស្នាជាគំរប់ពីរនោះទេវតាសួរថាដូចម្តេច ។

ព្រះមហាក្សត្រាធិរាជ មានព្រះឱ្ទូលថា ម្នាលអ្នកជាកុមារតូច ទេវតាសួរប្រស្នាទីពីរនេះថា សភាវមានតែពីរ ពុំដែលមានបី គឺសភាវអ្វី ។

ព្រះពោធិសត្វ ឆ្លើយថាបពិត្រមហារាជ សភាវមានតែ-

ពីរ ពុំដែលមានបីនោះគឺ ព្រះអាទិត្យ ១ ព្រះចន្ទ ១ ឯព្រះអា-ទិត្យនឹងព្រះចន្ទនេះ គឺអ្នកប្រាជ្ញទាំងឡាយលោកតែងពោលថា មានតែពីរក្នុងលោក បំណែកខាងព្រះអាទិត្យសំរាប់ភ្លឺរុងរឿងក្នុងវេលាថ្ងៃ ព្រះចន្ទសំរាប់ភ្លឺរុងរឿងក្នុងវេលាយប់ជាធម្មតាលោក ។ ព្រះសក្កទេវរាជបានស្តាប់ហើយ បើកនូវជុំវិញកាយនៃស្វេត្រឆត្រសំដែងនូវខ្លួនចេញមកពាក់កណ្ដាល ហើយពោលថាឱហ្ន៎ប្រស្នានេះគឺ កុមារនេះសំដែងហើយដោយប្រពៃ ពោលដូច្នេះហើយឱ្យសាធុការដោយសំឡេងដ៏ពីរោះហើយបាត់ទៅ ។

ព្រះបាទកោរព្យរាជ ព្រមទាំងសេវកាមាត្យ នូវមហាជនទាំងឡាយក៏ស្រែកឡើងស័ព្ទសាធុការដ៏លាន់ឮខ្លាំង មានសំ-ឡេងគឹកកងតែមួយ ។

លំដាប់នោះព្រះពោធិសត្វបានទូលសួរតទៅទៀតថា ប-ពិត្រមហារាជ ទេវតាសួរនូវប្រស្នាក្រៅពីនេះដូចម្តេចទៀត ។

សម្តេចព្រះនរទេពកោរព្យរាជ មានព្រះបន្ទូលថាម្នាលកុមារ ទេវតាសួរប្រស្នានឹងយើងថា សភាវមានតែបី ពុំដែលមានបួនគឺសភាវអ្វី ។

ព្រះមហាសត្តស្តាប់ហើយទូលថា បពិត្រមហារាជ វត្ថុអ្វីដទៃប្រាកដស្មើដោយព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃក្នុងលោកនេះពុំមានឡើយ ព្រះត្រៃសរណគមន៍ទាំងបីនេះគឺអ្នកប្រាជ្ញទាំងឡាយលោកពោលថា មានតែបីពុំដែលមានបួនដោយពិត ។

ព្រះឥន្ទនឹងព្រះបាទកោរព្យរាជព្រមទាំងរាជាមាត្យនូវមហាជនទាំងឡាយ បានស្តាប់ហើយក៏ឲ្យស័ព្ទសាធុការព្រមគ្នាក្នុងខណៈនោះឯង ។

ព្រះបរមពោធិសត្វ ក៏បានទូលសួរតទៅទៀតថា បពិត្រមហារាជ ទេវតាសួរនូវប្រស្នាក្រៅពីនេះដូចម្តេចទៀត ។

ព្រះបាទកោរព្យរាជ មានព្រះបន្ទូលថា ម្នាលកុមារទេវតាសួរប្រស្នានឹងយើងថា សភាវមានតែបួនពុំដែលមានប្រាំ គឺសភាវអ្វី ។

ព្រះពោធិសត្វឆ្លើយថា បពិត្រព្រះអង្គ មានតែបួនពុំដែលមានប្រាំនោះគឺទ្វីបធំទាំងបួន ឯទ្វីបធំទាំងបួននោះគឺ ជម្ពូទ្វីប ១ បុព្វវិទេហទ្វីប ១ អបរគោយានទ្វីប ១ ឧត្តរកុរុទ្វីប ១ គឺអ្នក

ប្រាជ្ញទាំងឡាយលោកពោលថាមានតែប្អូនជាធម្មតាលោក ពុំដែលមានប្រាជ្ញឡើយ ។

សម្ដេចព្រះអម្រិន្ទ្រាធិរាជ បានស្ដាប់ពាក្យវិសជ្ជនានៃព្រះ-ពោធិសត្វ ហើយញាំងផ្លៀងជាវិការនៃកែវប្រាំពីរប្រការ ឱ្យធ្លាក់ចុះមកបូជាព្រះបរមពោធិសត្វក្នុងកាលនោះឯង ។

ឯព្រះបាទគោរព្យរាជ បានឃើញកុមារជាអស្ចារ្យដូច្នោះហើយ លើកកុំបង់អញ្ជលីឡើងប្រណម្យពោលជាបទព្រះគាថាដូច្នេះថា ។

តាតត្វំអតិទហរោ មហាបញ្ញោសេដ្ឋោកុសលោ
តេគរិមហិសសតំ អស្សសតំហត្ថិសតំ
និក្ខសហស្សានិទទាមិ តេធម្មបូជនត្ថាយ ។

អធិប្បាយថា ម្នាលបាអ្នកឯងក្មេងក្រៃពេក ហើយឆ្លាតវៀងវៃមានប្រាជ្ញច្រើនដ៏ប្រសើរដោយវិសេស ដូច្នេះយើងបូជាគោ១រយ ក្របី១រយ សេះ១រយ ដំរី១រយ មាសដ្ឋោ១ពាន់ដល់អ្នក ដើម្បីប្រយោជន៍ដល់កិរិយាធ្វើឱ្យជាធម្មបូជាដល់អ្នក ។

គ្រានោះព្រះមហោសថ បានទូលសួរទៅស្ដេចវិញថា បពិត្រមហារាជ ទេវតាសួរនូវប្រស្នាឯណា សូមព្រះអង្គពោលនូវប្រស្នានោះមក ប្រស្នានោះតើដូចម្ដេច ។

ព្រះបាទកោរព្យរាជ ទ្រង់ព្រះសណ្ដាប់ហើយពោលថា ម្នាលបាជាកុមារតូចទេវតាសួរប្រស្នានឹងយើងថា សភាវមានតែប្រាំពុំដែលមានប្រាំមួយ គឺសភាវអ្វី ។

ព្រះពោធិសត្វបានស្ដាប់ហើយពោលថា បពិត្រមហារាជ ប្រស្នាជាគំរព់ប្រាំ ដែលទេវតាសួរហើយនោះ ទំងមានសភាវអ្វីដទៃប្រាកដស្មើដោយសីលប្រាំនេះពុំមានឡើយ ជនទាំង-ឡាយទាំងពួងរក្សានូវសីលទាំងឡាយប្រាំ តែច្យុតិអំពីមនុស្សលោកនេះហើយ រមែងបានទៅកើតជាទេវតានៅក្នុងតាវតិំស-ភព ដោយអានុភាពនៃសីលប្រាំ ព្រោះហេតុដូច្នោះ សីលទាំងប្រាំនេះ គឺអ្នកប្រាជ្ញទាំងឡាយពោលថា មានតែប្រាំ ពុំដែលមានប្រាំមួយដោយពិត ។

ឯសក្កទេវរាជបានស្ដាប់អធិប្បាយប្រស្នានេះហើយ ដល់នូវសេចក្ដីសោមនស្សជ្រះថ្លា បានយកនូវគ្រឿងក្រអូបនឹងគ្រឿង

លាបនឹងគ្រឿងអម្ពរទាំងឡាយដ៏ជាទិព្យ ធ្វើជាធម្មបូជាដល់ព្រះបរមពោធិសត្វ ។

ផង់ទាំងឡាយទាំងពួងក៏ផ្គងឡើងនូវអញ្ជលីនមស្ការថ្វាយបង្គំឱ្យស័ព្ទសាធុការដល់ព្រះបរមពោធិសត្វ ។

ឯព្រះបាទនរិន្ទ្រាធិបតី ស្តេចមានព្រះទ័យជ្រះថ្លា ហើយបានបូជានូវខ្ញុំស្រី ១ រយ ខ្ញុំប្រុះ ១ រយ មាសផ្តោ ១ ពាន់ដល់ព្រះបរមពោធិសត្វ ។

គ្រានោះព្រះបរមពោធិសត្វ ទូលសួរទៅទៀតថា បពិត្រមហារាជ ទេវតាសួរប្រស្នាដូចម្តេចទៀត សូមព្រះអង្គពោលនូវប្រស្នានោះមក ទូលបង្គំជាខ្ញុំនឹងអធិប្បាយឥឡូវនេះ ។

ព្រះបាទនរាធិបតីកោរព្យរាជ ទ្រង់ព្រះសណ្តាប់ហើយពោលថា ម្នាលបាកុមារតូច ទេវតាសួរប្រស្នានឹងយើងថា ស-ភាវមានតែប្រាំមួយ ពុំដែលមានប្រាំពីរ គឺសភាវអ្វី ។

គ្រានោះព្រះបរមពោធិសត្វ បានស្តាប់ហើយឆ្លើយថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ចុះ ទូលបង្គំជាខ្ញុំនឹងព្យាករណ៍ថ្វាយព្រះអង្គ ឯប្រស្នាថាសភាវមានតែប្រាំមួយ

ពុំដែលមានប្រាំពីរ នោះមិនគឺអ្វី គឺកាមាវចរសួគ៌ទាំងប្រាំមួយជាន់ គឺស្ថានចាតុមហារាជិកា ១ តាវតឹង្សា ១ យាមា ១ តុសិតា ១ និម្មានរតី ១ បរនិម្មិតវសវត្តី ១ ឋានសួគ៌ទាំងប្រាំមួយជាន់នេះគឺអ្នកប្រាជ្ញទាំងឡាយពោលថា មានតែប្រាំមួយពុំដែលមានប្រាំពីរដោយពិត ។

សម្តេចព្រះឥន្ទ្រាធិរាជ បានស្តាប់ហើយមានព្រះទ័យរីករាយ ប្រកបដោយបីតិនឹងសោមនស្ស ទ្រង់យកកែវទាំង ៧ ប្រការដាក់ក្នុងជើងពានមាស ដម្កល់ទៀបព្រះបាទព្រះបរមពោធិសត្វ ហើយធ្វើជាធម្មបូជាដល់ព្រះពោធិសត្វ ។

ឯស្តេចទាំងឡាយទាំងពួង មានព្រះបាទកោរព្យរាជជាដើមក៏បានបូជាកែវ ១ សែនដល់ព្រះបរមពោធិសត្វ ។

បំណែកខាងព្រះបរមពោធិសត្វ ទូលសួរតទៅទៀតថា បពិត្រមហារាជ ទេវតាសួរនូវប្រស្នាក្រៅពីនេះដូចម្តេចទៀត ។

ព្រះបាទកោរព្យរាជនោះ ទ្រង់ព្រះសណ្តាប់ហើយពោលថាម្នាលបាជាកុមារតូច ទេវតាសួរប្រស្នានឹងយើងថា សភាវមានតែប្រាំពីរ ពុំដែលមានប្រាំបី គឺសភាវអ្វី ។

ព្រះបរមពោធិសត្វ បានស្តាប់ហើយឆ្លើយថា បពិត្រមហារាជ ឯសភាវមានតែ ៧ ពុំដែលមាន ៨ នោះមិនគឺអ្វី គឺភ្នំសត្តបរិភណ្ឌទាំង ៧ ដែលជាបរិវារនៃភ្នំមេរុរាជ ( គឺភ្នំព្រះ-សុមេរុ ) ភ្នំសត្តបរិភណ្ឌទាំង ៧ នេះ គឺអ្នកប្រាជ្ញទាំងឡាយពោលថាមានតែ ៧ ពុំដែលមាន ៨ ដោយពិត ។

សម្តេចព្រះសហស្សនយន៍បមត្រ័យទិព្យ បានស្តាប់ហើយឲ្យសាធុការ ហើយយកកម្រងមាសមានដំឡៃ ១ សែនបូជាដល់ព្រះបរមពោធិសត្វ ។

គ្រានោះព្រះបរមពោធិសត្វ ទូលសួរតទៅទៀតថា បពិត្រមហារាជ ទេវតាសួរប្រស្នានឹងព្រះអង្គដូចម្តេចតទៅទៀត ។

ព្រះបាទកោរព្យរាជមហាបពិត្រ ទ្រង់ស្តាប់ហើយពោលថាម្នាលបាជកុមារតូច ទេវតាសួរប្រស្នានឹងយើងថា សភាវមានតែ ៨ ពុំដែលមាន ៩ គឺសភាវអ្វី ។

ព្រះបរមពោធិសត្វបានស្តាប់ហើយឆ្លើយថា បពិត្រមហា-រាជ ឯសភាវមាន ៨ ពុំដែលមាន ៩ នោះមិនគឺអ្វី គឺសីលដែល

ប្រកបព្រមដោយអង្គទាំង ៨ រកសភាវអ្វីដទៃឲ្យប្រាកដស្មើ ដោយសីល ៨ នេះពុំមានឡើយ . ព្រោះហេតុដូច្នោះសីល ទាំង ៨ នេះគឺអ្នកប្រាជ្ញទាំងឡាយពោលថាមានតែ ៨ ពុំដែល មាន ៩ ដោយពិត ។

សម្តេចព្រះអម្រិន្ទ្រាធិរាជ បានស្តាប់ហើយ បង្ហោរភ្លៀង ទិព្យបុះមកហើយបូជានូវផ្កាទិព្យដល់ព្រះបរមពោធិសត្វ ។

ឯពួកទេវតាទាំងឡាយ បានបូជាសម្ពត់ទិព្យនឹងកែវទាំង ៧ ប្រការដល់ព្រះបរមពោធិសត្វ ។

សម្តេចព្រះបមភារាកោរព្យរាជ បានឃើញនូវសេចក្តី អស្ចារ្យនោះហើយ ព្រះអង្គដល់នូវសេចក្តីសោមនស្ស បាន យកគ្រឿងអលង្ការមាសសុទ្ធនឹងប្រាក់បូជាដល់ព្រះបរមពោធិ- សត្វ ។

ឯស្តេចទាំងឡាយព្រមទាំងសេវកាមាត្យ មានសេនាប តីជាដើម បានបូជាមាសប្រាក់កែវមុក្តាកែវវេទូរិយ៍នឹងគ្រឿងអម្ព ទាំងឡាយ ហើយទូងនូវស្គរតូចស្គរធំប្លុងរគាំងនូវភ្លេងតូរ្យតន្ត្រី

ាំងពួងថ្វាយសព្ទសាធុការដល់ព្រះបរមពោធិសត្វដ៏លើសលប់ក្រពេក ។

ព្រះបរមពោធិសត្វ ក៏ទូលសួរតទៅទៀតថា បពិត្រមហា-រាជ ទេវតាសួរប្រស្នានឹងព្រះអង្គដូចម្ដេចតទៅទៀត ។

សម្ដេចព្រះមហៃស្វរសក្កកោរព្យរាជ ទ្រង់ស្ដាប់ហើយពោលថា ម្នាលបាជាកុមារតូច ទេវតាសួរប្រស្នានឹងយើងថា សភាវមានតែ ៩ ពុំដែលមាន ១០ គឺសភាវអ្វី ។

ព្រះបរមពោធិសត្វ បានស្ដាប់ហើយ សេចក្ដីអធិប្បាយប្រស្នានោះកើតប្រាកដដល់ព្រះអង្គមួយរំពេច ហើយឆ្លើយថាបពិត្រមហារាជ នឹងរកសភាវឯណាឲ្យប្រាកដស្មើដោយលោ-កុត្តរធម៌ទាំង ៩ ក្នុងលោកនេះពុំមានឡើយ ធម្មជាតិអ្វីដ៏ទៃប្រាកដស្មើដោយលោកុត្តរធម៌ទាំង ៩ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងមកហើយក្នុងលោកនេះក៏ពុំមានឡើយ លោកុត្តរធម៌នេះហើយគឺអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ពោលថាមានតែ ៩ ពុំដែលមាន ១០ ដោយពិត ។

សម្ដេចព្រះឥន្ទ្រកោសិយរាជ មានព្រះទ័យជ្រះថ្លាដោយ

កិរិយាធ្វើឲ្យជាក់ច្បាស់នូវប្រស្នានោះ ហើយឲ្យនូវគ្រឿងអម្ពរទិព្យទាំងឡាយនឹងញាំងផ្លៀងជាវិការនៃកែវទាំង ៧ ប្រការ ឲ្យធ្លាក់ចុះបូជាដល់ព្រះបរមពោធិសត្វ ។

ព្រះបាទកោរព្យរាជ បានឃើញនូវសេចក្ដីអស្ចារ្យដូច្នោះ ហើយមានព្រះរាជហឫទ័យត្រេកអរ បានបូជានូវរាជសម្បត្តិពាក់កណ្ដាល ដល់ព្រះបរមពោធិសត្វ ។

គ្រានោះភណ្ឌាគារិកកុមារពោធិសត្វ ទូលសួរតទៅ-ទៀតថា បពិត្រមហារាជ ប្រសិនមានដល់ព្រះអង្គដូចម្ដេច សូមព្រះអង្គពោលប្រស្នានោះមក ខ្ញុំនឹងដោះស្រាយក្នុងកាលឥឡូវនេះ ។

ព្រះបរមក្សត្រទ្រង់ព្រះសណ្ដាប់ហើយពោលថា ម្នាលបាជាកុមារតូច ទេវតាសួរប្រស្នានឹងយើងថា សភាវមានតែ ១០ ពុំដែលមាន ១១ គឺសភាវអ្វី ។

ព្រះមហាសត្វ បានស្ដាប់ហើយសំដែងថា បពិត្រពោរាជ សូមព្រះអង្គទ្រង់ស្ដាប់នូវពាក្យនៃខ្ញុំ ដ្បិតខ្ញុំប្រស្នាទាំងឡាយនោះប្រស្នាជាគំរប់ ១០ មកដល់ហើយ គុណជាតអ្វីប្រាកដស្មើ

ដោយសីល ១០ ក្នុងលោកពុំមានឡើយ សីល ១០ នេះហៅថា គហដ្ឋសីលជាសីលសម្រាប់គ្រហស្ថដែលជាអ្នកប្រាថ្នានូវ-បុណ្យធំតែងរក្សាជាប្រក្រតី សីលទាំង ១០ នេះគឺអ្នកប្រាជ្ញទាំងឡាយពោលថាមានតែ ១០ ពុំដែលមាន ១១ ឡើយដោយពិត ។

សម្តេចព្រះទេវានមិន្ទ្រាធិបតី បានស្តាប់ប្រស្នាព្យាករណ៍ព្រះបរមពោធិសត្វហើយ មានព្រះទ័យត្រេកអរសាទរ ញាំង-ផ្លៀងកែវ ៧ ប្រការនឹងផ្លៀងសំណាញ់ជាវិការនៃគ្រឿងអម្ពរនឹងកែវមុតាឲ្យធ្លាក់ចុះមក បីដូចជាមហាមេឃញាំងទឹកផ្លៀងឲ្យធ្លាក់ចុះមក ធ្វើជាធម្មបូជាដល់ព្រះបរមពោធិសត្វ ។

មិនតែព្រះឥន្ទ្រាធិរាជប៉ុណ្ណោះទេ ទោះទេវតាទាំងឡាយដែលស្ថិតនៅលើផែនដីក្តី ស្ថិតនៅលើដើមឈើទាំងពួងក្តីស្ថិតនៅលើអាកាសក្តី ស្ថិតនៅក្នុងកណ្តាប់ចក្កវាឡទាំងអស់ក្តីសឹងតែស្រែកឲ្យសព្វសាធុការ ដល់ព្រះបរមពោធិសត្វ ។

សម្តេចព្រះឥន្ទ្រាធិបតិកោរព្យរាជ ទ្រង់បានឃើញនូវសេចក្តីអស្ចារ្យប្លែកបំឡែកដូច្នោះហើយ ក៏ព្រះអង្គលើកយក

រាជសម្បត្តិទាំងអស់ធ្វើជាធម្មបូជា ដល់ព្រះបរមពោធិសត្វ ។

ឯស្តេចទាំងឡាយទាំងពួង អត់ទ្រាំពុំបានដោយសេចក្ដីជ្រះថ្លាខ្លាំងពេក ហើយនាំមកនូវព្រះរាជធិតានៃខ្លួនទីទៃ ៗ យកមកប្រគល់ថ្វាយដល់ព្រះបរមពោធិសត្វ ធ្វើឲ្យជាធម្មបូជា ។

ឯពួកសេវកាមាត្យទាំងឡាយក្ដី សិរីកញ្ញាទាំងឡាយក្ដី មហាជនទាំងឡាយទាំងពួងក្ដី ពួកពលទាហានសេនាយោធាទាំងអស់ក្ដី ទាំងខាងក្នុងនឹងខាងក្រៅនគរ បានបូជានូវគ្រឿងអម្ពរនឹងមាសប្រាក់កែវមុក្តាកែវមណី នឹងសម្ពត់ទាំងឡាយ ហើយញ៉ាំងទង់កំណាត់សម្ពត់ឲ្យប្រព្រឹត្តទៅ ប្រគំនូវភ្លេងតូរ្យតន្ត្រីទាំងពួងមានវាទតពាតគងនឹងស្គរតូចស្គរធំជាដើម បូជាដល់ព្រះបរមពោធិសត្វ ។

ក្នុងខណនោះ ផែនដីធំកម្រើកញាប់ញ័រហាក់បីដូចជាបែកជាពីរ ។

គ្រានោះសម្ដេចអមរិន្ទ្រាធិរាជ បានញ៉ាំងខ្លួនឲ្យព្រះបាទកោរព្យរាជ ព្រមទាំងសេវកាមាត្យនូវមហាជនទាំងឡាយ ឲ្យបានស្គាល់ដឹងច្បាស់ហើយ ពោលជាបទព្រះគាថាដូច្នេះថា

សក្កោហមស្មិទេវិន្ទោ អាគតោភវិសន្តិកេ
បុញ្ហាំបុច្ឆិបកោវព្យោ រាជាអត្ថំនបស្សតិ
តួមេវិបញ្ហោព្យាកាសិ សាធុការំទទាមិតេ
សាធុសាធុមហាវិរ សម្បន្នំតេមនោរថំ
អចិរេនតុរិកាលេ ពុទ្ធោលោកេភវិស្សសិ
វិរេវិរសុកុមារ ។

អធិប្បាយថា ខ្ញុំជាព្រះឥន្ទ្រជាធំជាងទេវតា បានមកហើយក្នុងសំណាក់នៃព្រះអង្គ មានស្តេចទ្រង់ព្រះនាមកោរព្យជាប្រធាន ដែលខ្ញុំបានសួរនូវប្រស្នាឯណា ពុំបានឃើញនូវសេចក្តីអធិប្បាយនៃប្រស្នានោះ មានតែអ្នកជាកុមារតូចទើបធ្វើឲ្យជាក់ច្បាស់នូវប្រស្នាទាំងឡាយបាន បពិត្រកុមារមានព្យាយាមធំប្រពៃៗហើយ ខ្ញុំឲ្យនូវសាធុការដល់អ្នក សេចក្តីប្រាថ្នាក្នុងចិត្តអ្នកបរិបូណ៌ហើយ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដក្នុងលោកក្នុងកាលពុំយូរប៉ុន្មាន ម្នាលកុមារ អ្នកចូលទទួលយកនូវពរទាំងឡាយ ។

ឯភណ្ឌាគារិកកុមារព្រះពោធិសត្វ កាលបានទទួលយក

នូវពរទាំង ៤ អំពីសំណាក់ព្រះឥន្ទ្រាធិរាជហើយពោលជាបទព្រះគាថាដូច្នេះថា ។

វរញ្ចេមេអទោសក្ក សព្វភូតានមិស្សរោ
បិតាមំអនុមោទេយ្យ ឥតោបត្តំសកំឃរំ
អាសនេននិមន្តេយ្យ បឋមេតំវរំវរេ ។

អធិប្បាយថា បពិត្រសក្កទេវរាជ ថាបើព្រះអង្គឲ្យនូវពរដល់ខ្ញុំ ព្រះបិតាដែលជាឥស្សរធំជាងសត្វទាំងឡាយទាំងពួងគប្បីរីករាយតាមនូវខ្ញុំ គប្បីហៅរកនូវខ្ញុំបានមកដល់ផ្ទះជារបស់នៃខ្លួនដោយទីអាសនអំពីកាលនេះ ព្រះអង្គគប្បីឲ្យនូវពរនេះជាបឋមឲ្យបានសម្រេចដល់ខ្ញុំ ។

បុរិសវធន្នរោចេយ្យំ អបិកិព្វិសការកំ
វជ្ឈំវធម្ហាមោចេយ្យំ ទុតិយេតំវរំវរេ

អធិប្បាយថា ខ្ញុំមិនគប្បីគាប់ចិត្តនូវកិរិយាសម្លាប់នូវបុរសម្យ៉ាងវិញទៀតខ្ញុំគប្បីដោះលែងនូវបុរសអ្នកធ្វើនូវអំពើអាក្រក់គឺបុគ្គលកាលសម្លាប់ឲ្យរួចអំពីស្លាប់ ព្រះអង្គគប្បីឲ្យនូវពរនេះជាគំរប់ពីរឲ្យបានសម្រេចដល់ខ្ញុំ ។

យេវុឌ្ឍាយេបទហរា យេបចមជ្ឈិមបោរិសាំ
មមេវឧប្បជ្ជិវេយ្យុំ តតិយេតិវិរវេ

អធិប្បាយថា ជនទាំងឡាយឯណាចាស់ក្តី ជនទាំង-ឡាយឯណាក្មេងក្តី ជនទាំងឡាយឯណាជាបុរសកណ្តាលក្តី ជនទាំងឡាយទាំងពួងនោះ ៗ គប្បីអាស្រ័យនូវខ្ញុំហើយរស់នៅមែនពិត ព្រះអង្គគប្បីឲ្យនូវពរនេះជាគំរប់បី ឲ្យបានសម្រេចដល់ខ្ញុំ ។

បរទារំនគច្ឆេយ្យំ សទារបសុតោសិយំ
ថីនំវសំនគច្ឆេយ្យំ អភតំសព្វបាណិនំ
អហមេវសក្កជាយេថ រាជានោបទិឃាយុកោ
ធម្មេនជិនេបថវិំ អធម្មោធម្មរក្ខិតោ-
ទទតោមេនខិយេត្ថ ទត្វានុតប្បេយ្យហំ
ទទំចិត្តំបសាទេយ្យំ បតុត្ថេតិវិរវេ ។

អធិប្បាយថា ខ្ញុំមិនគប្បីគប់នូវប្រពន្ធនៃបុគ្គលដទៃ ខ្ញុំខ្វល់ខ្វាយហើយក្នុងប្រពន្ធនៃខ្ញុំនគប្បីមាន មិនគប្បីលុះក្នុងអំណាចនៃស្រីទាំងឡាយ បពិត្រសក្កទេវរាជ ខ្ញុំគប្បីញ៉ាំងអំពើ

គឺបុគ្គលមិនត្រូវធ្វើឱ្យកើតដល់សត្វទាំងឡាយទាំងពួង ស្តេចនៃយើងទាំងឡាយសូមព្រះអង្គមានជន្មវែង បើព្រះអង្គពុំមានធម៌ឱ្យជាអ្នករក្សានូវធម៌វិញ ហើយគប្បីឈ្នះនូវផែនដីគឺគ្រប់គ្រងរក្សានូវផែនដីដោយធម៌ ចិត្តសទ្ធារបស់ខ្ញុំកាលឱ្យទានមិនគប្បីអស់ទៅ ខ្ញុំបានឱ្យនូវទានហើយមិនគប្បីក្តៅក្រហាយចិត្តរឿយ ៗ ជាខាងក្រោយ ខ្ញុំកាលឱ្យនូវទានគប្បីញ៉ាំងចិត្តនៃខ្លួនឱ្យជ្រះថ្លា ព្រះអង្គគប្បីឱ្យនូវពរនេះជាគំរប់ ៤ ឱ្យបានសម្រេចដល់ខ្ញុំ ។

សម្តេចព្រះមឃវាតន្រ្ទាធិរាជ បានពោលថាព្រះបិតានៃអ្នកត្រូវស្រោចទឹកអភិសេកនូវអ្នកដោយកាលមិនយូរ សម្តេចព្រះសុជម្បតិទេវរាជ បានពោលដូច្នេះក៏ហោះទៅឋានសួគ៌វិញហោង ។

គ្រានោះព្រះចៅក្រុងកៃកោរព្យរាជ បានញ៉ាំងកុមារឱ្យងូតទឹកជម្រះរាងកាយហើយឱ្យបរិភោគនូវភោជនដ៏មានរសប្រ-ពៃហើយឱ្យប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ស្តេចពុំទាន់

ស្គាល់កុមារថាជាបុត្រារបស់ព្រះអង្គឡើយ លើកកុមារឲ្យអង្គុយ លើព្រះឱរុព្រះអង្គ ហើយពោលនូវគាថាដូច្នេះថា ។

ហាតាតបិយបុត្តក តញ្ញបុត្តំនជានាមិ
តវមាតាកុហិំដ្ឋានេ តំមេអក្ខាហិបុច្ឆិតោ ។

អធិប្បាយថា ហែអ្នកជាកូនតូចសំឡាញ់ យើងក៏ពុំទាន់បានស្គាល់អ្នកថាជាបុត្តអ្នកឯណា មាតារបស់អ្នកស្ថិតនៅក្នុងទីឯណា អ្នកគឺយើងសួរនូវហេតុនោះចូលអ្នកប្រាប់នូវហេតុនោះដល់យើង ។

ព្រះបរមពោធិសត្វ បានស្តាប់ពោលជាបទព្រះគាថា. ដូច្នេះថា ។

អត្ថិមាតាយរេតិដ្ឋ ភណ្ឌាគារោបរក្ខិត
សត្តវស្សេសត្តមាសេ យាវសត្តទិវសេសុ
ត្វញ្ចជានាសិឥស្សរោ អត្តនោបុត្តំនជានាសិ
អហញ្ចតវបុត្តោវ តុវំជានាហិខត្តិយ ។

អធិប្បាយថា មាតារបស់ខ្ញុំមានស្ថិតនៅក្នុងផ្ទះ នាយឃ្លាំងរក្សាទុកដោយប្រពៃ កន្លងទៅបាន ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ

ហើយ ឯព្រះអង្គជាឥស្សរធំជ្រាបដែរតែហាក់ដូចជាមិនជ្រាបនូវបុត្រារបស់ខ្លួន បំណែកខាងខ្ញុំជាបុត្រារបស់ព្រះអង្គពិត បពិត្រមហារាជ្យត្រូវសូមព្រះអង្គទ្រង់ជ្រាប ។

ព្រះបរមភពកោរព្យរាជ ព្រះអង្គបានស្តាប់កុមារក្រាបទូលដូច្នោះហើយ ទ្រង់ជ្រាបច្បាស់ថាជាបុត្រារបស់ព្រះអង្គពិត ពោលជាបទព្រះគាថាទៅនឹងនាយឃ្លាំងថា:

ឧដ្ឋេហិកត្តេតរមានោ សព្វសេនានិយោសិត្តំ
ហត្ថិអស្សរថាបត្តិ សេនាយបតុរង្គិនិ
បរិសិត្វារាជគហេ សព្វាកញ្ញាសហស្សានិ
សព្វាលង្ការភូសិតា និយោសិត្វាសព្វាតាយោ
បរិស្សន្តុបុរំរម្មំ ។

អធិប្បាយ ម្នាលនាយឃ្លាំងជាអ្នកជាត់ការ ត្រូវអ្នកក្រោកឡើងរួសរាន់ចូលទៅក្នុងគេហស្ថាន យោស្នាប្រាប់សេនាទាហានទាំងឡាយប្រកបដោយអង្គ ៤ គឺសេនាដំរីសេនាសេះសេនារថសេនាពលថ្មើរជើង ហើយយោស្នាប្រាប់នាងកញ្ញាទាំង ១ ពាន់ឲ្យប្រដាប់ស្អិតស្អាងគ្រឿងអលង្ការទាំងពួង រួបហើយ

នាងកញ្ញាទាំងអស់នឹងសេនាទាំងពួងនោះ ត្រូវទៅយកនាងសុមនទេវី ដង្ហែចូលមកកាន់បុរីដែលជាទីដំរេកឲ្យឆាប់រួសរាន់ៗ

នាយឃ្លាំងបានទទួលព្រះរាជឧង្ការត្រាស់បង្គាប់ហើយ បាត់ការនោះសព្វគ្រប់ ដោយឆាប់រួសរាន់ ទៅដង្ហែនាំយកព្រះនាងទេវីចូលមកកាន់ព្រះបរមរាជវាំងវិញ ។

ឯព្រះបាទកោរព្យរាជ ចាំមើលផ្លូវនាងទេវីបានឃើញនាងទេវីមកដល់ហើយ ព្រះអង្គក៏ចុះទៅទទួលចាប់ដៃព្រះនាងទេវីនាំឡើងលើប្រាង្គណ៍ប្រាសាទហើយគង់នៅលើអាសនជាមួយនឹងនាងទេវី ហើយប្តេជ្ញាទោសនឹងនាងទេវី ស្រេចហើយស្តេចព្រាំងនាងទេវីឲ្យងូតដោយទឹកក្រអូប ស្រោចទឹកអភិសេក ហើយឲ្យប្រដាប់ស្អិតស្អាងគ្រឿងអលង្ការ ឲ្យបរិភោគភោជនដ៏មានរសប្រពៃ ហើយដម្កល់ក្នុងទីជាអគ្គមហេសីធំដ៏ប្រសើរក្នុងកាលនោះឯង ។

សម្តេចព្រះបរមពោធិវង្កុល ពន្លកបណ្តូលសម្ពោធិញាណ ព្រះអង្គបានទទួលរាជាភិសេកតាំងពីព្រះជន្មជាង ៧ ឆ្នាំឬាយឡើងទៅសោយរាជសម្បត្តិជាស្តេចឯករាជទ្រង់ទសពិតរាជធម៌

ទាំង ១០ មានព្រះរាជហឫទ័យស្មើ ផ្សាយទៅសព្វសត្វទាំងអស់ ហើយបានព្រះទានសម្បត្តិយ៉ាងធំដល់នាយឃ្លាំងដែលជាអ្នកបិញ្ចិមរក្សាព្រះអង្គពីកុមារត្តូចមក ដោយឥស្សរយសដ៏ប្រសើរៗ

ឯស្ដេចទាំងឡាយទាំងពួង ក៏លើកយករាជសម្បត្តិរបស់ខ្លួនទីទៃ ៗ ថ្វាយដល់ព្រះបរមពោធិសត្វ ហើយធ្វើប្រដាប់នូវធិតានៃខ្លួនទីទៃ ៗ ដ៏ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងស្រេចហើយប្រគល់ថ្វាយដល់ព្រះបរមពោធិសត្វ ផ្គងឡើងនូវអញ្ជលីនមស្សការថ្វាយបង្គំហើយស្ថិតនៅ ។

សម្ដេចព្រះបាទភណ្ឌាគារិករាជបរមពោធិសត្វ ព្រះអង្គឲ្យនូវឱវាទដល់ស្ដេចទាំងឡាយនោះថា អ្នកទាំងឡាយចាប់ដើមអំពីថ្ងៃនេះទៅ ចូរកុំប្រមាទត្រូវរក្សាសីល ៥ ឲ្យខ្ជាប់ត្រូវចំរើណាមេត្តាភាវនាជានិច្ច ត្រូវសន្សំនូវបុណ្យមានប្រមាណតិច ៗ ជាស្បៀងអាហារទៅកាន់បរលោក ហើយទ្រង់ហាមថែមទៀតថា ស្ដេចទាំងឡាយមិនគប្បីសម្លាប់សត្វ មិនគប្បីកាន់យកនូវទ្រព្យនៃបុគ្គលដទៃ មិនគប្បីគប់នូវប្រពន្ធកូននៃបុគ្គលដទៃ មិនគប្បីពោលនូវពាក្យកុហក មិនគប្បីផឹកនូវទឹកស្រវឹងគឺសុរា

និងមេរ័យ ត្រូវឲ្យនូវទានត ៗ ទៅកុំឲ្យដាច់ ព្រះបរមពោធិសត្វឲ្យឱវាទដល់ស្តេចទាំងឡាយនោះ ស្រេចហើយប្រជុំនូវស្តេចទាំងឡាយមកជុំហើយប្រគល់នូវរាជសម្បត្តិឲ្យវិញ ហើយបញ្ជូននូវស្តេចទាំងឡាយនោះឲ្យទៅកាន់នគរនៃខ្លួនទីទៃៗវិញ ។

ព្រះបរមពោធិសត្វ ព្រះអង្គសោយរាជសម្បត្តិ ទ្រង់ទសពិធរាជធម៌ទាំង ១០ រក្សាសីល ៥ សីលឧបោសថប្រកបដោយអង្គ ៨ ហើយបរិច្ចាគព្រះរាជទ្រព្យធ្វើបុណ្យឲ្យទានពុំដែលដាច់ ដល់ព្រះអង្គទ្រង់ព្រះទីវង្គតរំលត់ព្រះជន្មទៅបានបង្កើតក្នុងស្ថានទេវលោក សោយទិព្វសម្បត្តិជាសុខក្សេមក្សាន្តប្រកបដោយទិព្វទាំង ១០ ប្រការ ។

អង្គសម្តេចព្រះសព្វញ្ញុតញ្ញាណជាម្ចាស់ ព្រះអង្គនាំអតីតនិទាននេះមកសំដែងចប់ហើយ ទ្រង់ប្រជុំនូវជាតកពោលជាបទព្រះគាថាដូច្នេះថា

សុមនទេវីទុក្ខប្បត្តា   មហាមាយាឥទានិបិ
កោរព្យោបមហារាជា   បិតាសុទ្ធោទនោអហុ

សក្កោអនុរុទ្ធោអាសិ ទិព្វចក្ខុអនុត្តរោ

ភណ្ឌាគារញ្ញរក្ខត្តោ អានន្ទោយោគត្តាបិច

សព្វសេនាចាមច្ចាច ពុទ្ធបរិសាវអហុ

ភណ្ឌាគារកុមារោច ពោធិសត្តោសព្វបារមិ

សព្វញ្ញូលោកនាថោសោ ឯវំធារេថជាតកំ ។

អធិប្បាយថា នាងសុមនទេវីដែលដល់នូវសេចក្ដីទុក្ខ វិលមកមែនក្នុងកាលឥឡូវនេះ បានមកជាសិរិមហាមាយាជាពុទ្ធមាតា ព្រះបាទកោរព្យមហារាជវិលមកក្នុងកាលឥឡូវនេះ បានជាព្រះបាទសុទ្ធោទនជាពុទ្ធបិតា សម្ដេចព្រះអម្រិត្រាធិរាជដែលមានព្រះនេត្រដ៏ជាទិព្វដ៏លើសលប់ដោយវិសេស្ស វិលមកក្នុងកាលឥឡូវនេះ បានជាព្រះថេរឈ្មោះអនុរុទ្ធ ម្យ៉ាងវិញទៀតនាយឃ្លាំងជាអ្នកធ្វើការឯណា កាលរក្សានូវភណ្ឌាគារិកកុមារ នាយឃ្លាំងនោះវិលមកក្នុងកាលឥឡូវនេះ បានជាព្រះថេរឈ្មោះអានន្ទ សេនាទាំងឡាយទាំងពួង វិលមកក្នុងកាលឥឡូវនេះ

បានជាពុទ្ធបរិសទ្យទាំងអស់ ភណ្ឌាគារិកកុមារពោធិសត្វឯណាបានបំពេញនូវបារមីទាំងពួង ពោធិសត្វនោះវិលមកក្នុងកាលឥឡូវនេះ បានត្រាស់ជាព្រះពុទ្ធជាអង្គសព្វញ្ញូជាទីពឹងនៃសត្វលោក អ្នកទាំងឡាយចូរទ្រទ្រង់នូវជាតកយ៉ាងនេះហោង ។៚—

សំដែងរឿងប្រស្នាព្រះឥន្ទសួរស្ដេចកោរព្យរាជ

ក្នុងភណ្ឌាគារិកជាតកចប់សេចក្ដីជាសង្ខេបតែប៉ុណ្ណោះឯង ។